# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

**ភាគីដាក់ឯកសារ:** ក្រុមមេធាវីការពារក្តី នួន ជា

**ដាក់ជូន:** អង្គជំនុំជម្រះតុលាការកំពូល

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Feb-2016, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាតុលាការកំពូល:** សាធារណៈ/Public

**ចំណាត់ថ្នាក់ប្រភេទឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

## សំណើរបស់ នួន ជា សុំឲ្យពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការមិនកោះហៅសាក្សី ហេង សំរិន និង ROBERT LEMKIN និងសុំឲ្យទទួលយកភស្តុតាងរបស់ ROBERT LEMKIN នៅក្នុងដំណើរការបណ្តឹងសាទុក្ខ

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

លីវ សុវណ្ណា

ព្រុំ ផល្លា

Doreen CHEN
Léa KULINOWSKI
Xiaoyang NIE
Marina HAKKOU

**ផ្ញើជូន៖**

**សហមេធាវីការពារក្តី ខៀវ សំផន៖**

គង់ សំអុន

Anta GUISSÉ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

## I. សេចក្តីផ្តើម

1. នៅក្នុងដំណើរការបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០១ សហមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") បានដាក់សំណើសុំភ័ស្តុតាងបន្ថែមមួយចំនួនសម្រាប់បណ្តឹងសាទុក្ខ។ មេធាវីការពារក្តីបានស្នើសុំឲ្យកោះហៅសាក្សីចំនួន ១៦ នាក់ដើម្បីមកផ្តល់សក្ខីកម្មក្នុងដំណើរការបណ្តឹងសាទុក្ខ ឲ្យទទួលយកភ័ស្តុតាងបន្ថែមចំនួន ៣៩ និងឲ្យស្វែងរកភ័ស្តុតាងបន្ថែមមួយចំនួន រួមមានតាមរយៈការផ្តួចផ្តើមឲ្យមានការស៊ើបអង្កេតនៅក្នុងហេតុការណ៍មួយដែលរងការចោទប្រកាន់[1]។ នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលជាច្រើននៅក្នុងសំណើសុំទាំងនេះ ("សេចក្តីសម្រេចលើសំណើសុំ")[2]។ សេចក្តីសម្រេចផ្តល់គ្រាន់តែជាលក្ខណៈនៃសេចក្តីសម្រេច ហើយមិនមែនជាសេចក្តីសម្រេចដែលមានសម្អាងហេតុពេញលេញ ដែលអង្គជំនុំជម្រះបញ្ជាក់ថា "នឹងចេញក្នុងពេលសមស្រប"[3]។ នាពេលនេះ មេធាវីការពារក្តីសូមដាក់សំណើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណាឡើងវិញលើផ្នែកខ្លះនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការមិនកោះហៅសាក្សី ហេង សំរិន និង Robert Lemkin និងការមិនទទួលយកភស្តុតាងកំណត់ត្រា ("កំណត់ត្រា") និង ផ្នែកស្ទើរតែទាំងអស់នៃប្រតិចារិក ("ប្រតិចារិក") ដែល Robert Lemkin បានផ្តល់ជូនអង្គជំនុំជម្រះដើម្បីជាឯកសារចំពោះបទសម្ភាសន៍ដែលគាត់ និង ថេត សម្បត្តិបានធ្វើឡើងជាមួយកម្មាភិបាលជាន់ខ្ពស់បក្សកុម្មុយនិស្តកម្ពុជានៃភូមិភាគពាយ័ព្យ ("សំណើ")។

---

[1] ភ័ស្តុតាងបន្ថែមដែលត្រូវស្វែងរក/ការស៊ើបអង្កេតដែលត្រូវធ្វើឡើង៖ (១) ភ័ស្តុតាងដែលបានយោងនៅក្នុងកិច្ចសម្ភាសន៍ ថេត សម្បត្តិ ជាមួយនឹងវិទ្យុផ្សាយសម្លេងរបស់សហរដ្ឋអាមេរិកជាភាសាខ្មែរនៅថ្ងៃទី ១២ និងថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ (*នៅក្នុង*ឯកសារ **F2** សំណើលើកទីមួយសុំភ័ស្តុតាងបន្ថែម កថាខណ្ឌ ១៨(ខ) និង*នៅក្នុង*ឯកសារ **F16** បណ្តឹងសាទុក្ខ កថាខណ្ឌ ៧៣០(ខ)) (២) ភ័ស្តុតាងមួយចំនួនពីក្នុងសំណុំរឿង ០០៣ និង០០៤ (ដែលនឹងដាក់បង្ហាញដោយសហព្រះរាជអាជ្ញា) (ឯកសារ **F2/4** សំណើលើកទីបីសុំភ័ស្តុតាងបន្ថែម កថាខណ្ឌ ៣៤(គ)) និង (៤) (៥) (៦) និង (៧) កិច្ចស៊ើបសួរចំនួន ៤ ដើម្បីផ្ទៀងផ្ទាត់ជាមួយនឹងសក្ខីកម្មរបស់ សំ សិទ្ធី ទាក់ទងនឹងហេតុការណ៍ដែលបានចោទប្រកាន់ (*នៅក្នុង*ឯកសារ **F28** "សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍នានាដែលពិពណ៌នានៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់ សំ សិទ្ធី" ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ៣១)។

[2] ឯកសារ **F2/9** "សេចក្តីសម្រេចលើសំណើសុំដាក់ភ័ស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ និងបញ្ហាពាក់ព័ន្ធ - ផ្នែកសម្រេចសេចក្តី-" ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ ("សេចក្តីសម្រេចលើសំណើសុំ")។

[3] ឯកសារ **F2/9** "សេចក្តីសម្រេចលើសំណើសុំ" ទំព័រ ៦ ដល់ ៧។

## II. សាវតារ

### ក. សេចក្តីសម្រេចលើសំណើសុំដែលមិនទាន់បានសម្រេច

2. សំណើរបស់មេធាវីការពារក្តីស្នើសុំសាក្សី និងភស្តុតាងបន្ថែម មានរហូតទៅដល់១០ ដែលបានដាក់ជូនដោយមេធាវីការពារក្តីនៅរវាងខែ កញ្ញា ឆ្នាំ២០១៤ ដល់ ខែ តុលា ឆ្នាំ២០១៥។ នៅក្នុងចំណោមសំណើទាំងនេះមានមួយចំនួនទាក់ទងនឹងភស្តុតាងដែលជាកម្មសិទ្ធិរបស់ផលិតករខ្សែភាពយន្ត*សត្រូវប្រជាជន* គឺ ថេត សម្បត្តិ និង Robert Lemkin[4]។ បន្ថែពីលើនេះ សំណើលើកទីប្រាំ និងទីប្រាំមួយសុំភស្តុតាងបន្ថែម (ជាបន្តបន្ទាប់ថាជា "សំណើលោកទីប្រាំសុំភស្តុតាងបន្ថែម និងសំណើទីប្រាំសុំភស្តុតាងបន្ថែម") បានបង្ហាញលម្អិតអំពីភស្តុតាងដែលភាគច្រើនត្រូវបានបង្ហាញមកពីសំណុំរឿង ០០៣ និង ០០៤។ ភស្តុតាងទាំងអស់នេះបានចោទប្រកាន់ថា មានការបះបោរផ្ទៃក្នុង និង រដ្ឋប្រហារ ត្រូវបានរៀបចំឡើងដោយកម្មាភិបាលភូមិភាគពាយ័ព្យ ឧត្តរ និង បូព៌ា និងកងពលរបស់ភូមិភាគទាំងនេះ[5]។

3. អង្គជំនុំជម្រះតុលាការកំពូលបានយល់ព្រមតាមសំណើសុំភ័ស្តុតាង និងសាក្សីមួយចំនួនរបស់មេធាវីការពារក្តីនៅក្នុងដំណាក់កាលដំបូងៗនៃបណ្តឹងសាទុក្ខ ហើយអ្វីដែលគួរឲ្យកត់សម្គាល់បំផុតនោះ គឺតាមរយៈការកោះហៅសាក្សីបីរូប[6] និងបើកការស៊ើបអង្កេតលើភ័ស្តុតាងដែលមាននៅ

---

[4] **F2** "សំណើសុំឲ្យទទួល និងពិចារណាទៅលើភ័ស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៤ ("សំណើលើកទីមួយសុំភ័ស្តុតាងបន្ថែម")។ **F2/4/3/3/1** "ចម្លើយតបរបស់ នួន ជា ទៅនឹងសំណួរនានាស្តីអំពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងឃុតវីដេអូ ដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត ROBERT LEMKIN និង ថេត សម្បត្តិ" ១៣ កក្កដា ២០១៥។ ឯកសារ **F2/4/3/3/6/1** "សារណារបស់ នួន ជា អំពីប្រតិចារិតរបស់ ROBERT LEMKIN និងសារសំខាន់នៃជម្លោះក្នុង ប.ក.ក" ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១៥ ("សារណាអំពីប្រតិចារិត និង "ជម្លោះ")

[5] ឯកសារ **F2/7** "សំណើទីប្រាំរបស់ នួន ជា សុំឲ្យពិចារណា និងទទួលយកភ័ស្តុតាងបន្ថែមពាក់ព័ន្ធបណ្តឹងសាទុក្ខប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ ("សំណើលើកទីប្រាំសុំភ័ស្តុតាងបន្ថែម")។

[6] ឯកសារ **F2/5** "សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ" ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ កថាខណ្ឌ ២៦។

ក្នុងដៃរបស់ ថេត សម្បត្តិ និង Robert Lemkin[7]។ ទោះបីជាយ៉ាងនេះក្តី សំណើសុំភាគច្រើនរបស់មេធាវីការពារក្តីត្រូវបានសម្រេចនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ លើសំណើសុំដែលមិនបានសម្រេច ពោលគឺ បានចេញក្នុងរយៈពេលតែបីសប្តាហ៍ នៅមុនពេលសវនការបណ្តឹងសាទុក្ខចុងក្រោយគ្រោងនឹងចាប់ផ្តើម *និងរយៈពេល១៣ខែ*បន្ទាប់ពីមេធាវីការពារក្តីបានដាក់សំណើលើកទីមួយរបស់ខ្លួន[8]។ សេចក្តីសម្រេចនោះច្រានចោលសំណើសុំរបស់មេធាវីការពារក្តីរួមគ្នាតែម្តង។ លើសពីនេះ សេចក្តីសម្រេចនេះបានបង្ហាញតែផ្នែកនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើសំណើសុំទាំងនោះ ដោយពុំបានផ្តល់សំអាងហេតុ ហើយដែលអង្គជំនុំជម្រះបានចង្អុលបញ្ជាក់ថានឹង "ចេញជូនតាមក្រោយក្នុងពេលសមស្របខាងមុខ"[9]។

4. មេធាវីការពារក្តី និង នួន ជា មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះសេចក្តីសម្រេចលើសំណើសុំដែលមិនទាន់សម្រេចទាំងនេះ។ មេធាវីការពារក្តីបានអះអាងថា គ្រប់ភស្តុតាងបន្ថែមដែលបានស្នើសុំគឺមានការទាក់ទងខ្លាំងណាស់ទៅនឹងការកំណត់របស់អង្គជំនុំជម្រះតុលាការកំពូលទៅលើបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០១ គឺបានបំពេញតាមវិធាន ១០៨(៧) និងតាមពិតភស្តុតាងភាគច្រើនវាអាចជា *"កត្តាកំណត់នាំឲ្យឈានទៅដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ"*[10]។ តាមរយៈនេះ មេធាវីការពារក្តីគិតថា គឺមិនមានហេតុផលសមស្របណាមួយសម្រាប់ការបដិសេធទៅនឹងសំណើនោះទេ ដូចដែលបានពិភាក្សាលម្អិតខាងក្រោម[11]។ តែទោះជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះ មិនបានផ្តល់សូម្បីតែសេចក្តីសង្ខេបសម្អាងហេតុទាល់តែ

---

[7] ឯកសារ **F2/4/3** "សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើទីមួយរបស់ នួន ជា សុំឲ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ កថាខណ្ឌ ២៦។

[8] សំណើលើកទីមួយរបស់មេធាវីការពារក្តីស្នើសុំឲ្យសាក្សីផ្តល់សក្ខីកម្មលើបណ្តឹងសាទុក្ខ ដែលបានដាក់នៅថ្ងៃទី ១ កញ្ញាឆ្នាំ ២០១៤ សូមមើល **F2** "សំណើលើកទីមួយសុំភស្តុតាងបន្ថែម"។

[9] ឯកសារ **F2/9** សេចក្តីសម្រេចលើសំណើសុំ ទំព័រ ៦-៧។

[10] បញ្ជាក់បន្ថែម។ វិធានផ្ទៃក្នុង អវតកអនុញ្ញាតឲ្យទទួលយកភស្តុតាងថ្មី និងពិចារណាលើបណ្តឹងសាទុក្ខ។ នៅវិធាន ១០៤(១) អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង "អាចបើកការពិនិត្យភស្តុតាង និងស្វែងរកភស្តុតាងថ្មី" នៅក្នុងការសម្រេចលើបណ្តឹងសាទុក្ខ។ តែវិធាន ១០៨ (៧) អនុញ្ញាតឲ្យភាគីស្នើអង្គជំនុំជម្រះទទួលយកភស្តុតាងបន្ថែម "ដោយបង្ហាញថា មិនអាចរកបាននៅមុនពេលសវនការ ហើយដែលអាចជាកត្តាកំណត់នាំឲ្យឈានទៅដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ"

[11] សូមមើលកថាខណ្ឌ ៣០ខាងក្រោម។

សោះ មិនបាច់និយាយដល់សម្អាងហេតុពេញលេញនោះទេ[12] បើទោះជាពេលវេលាហួសផុតទៅរវាងសំណើរបស់មេធាវីការពារក្តី និង សេចក្តីសម្រេចលើសំណើនេះ និងការពិតដែលថា សេចក្តីទាក់ទងនឹងបញ្ហានេះគឺពិតជាសំខាន់ណាស់សម្រាប់មេធាវីការពារក្តី។ សម្រាប់ហេតុផលនេះ សេចក្តីសម្រេចបដិសេធលើសំណើរបស់មេធាវីការពារក្តី បានធ្វើឲ្យតក់ស្លុតយ៉ាងខ្លាំង។ ធ្វើឲ្យស្ថានការកាន់តែអាក្រក់នោះ គឺអង្គជំនុំជម្រះចេញសេចក្តីសម្រេចនៅក្នុងអំឡុងពេលសម្រាក ដើម្បីត្រៀមខ្លួនសម្រាប់សវនាការលើបណ្តឹងសាទុក្ខ ដែលជាពេលវេលាមួយមមាញឹកបំផុត និងត្រឹមតែផ្តល់ពេលប៉ុន្មានសប្តាហ៍ នៅមុនពេលច្រកលទ្ធភាពរបស់មេធាវីការពារក្តីក្នុងការធ្វើសារណាជាលាយលក្ខណ៍អក្សរដាក់ជូនអង្គជំនុំជម្រះតុលាការកំពូល នឹងត្រូវបិទទ្វារជាអចិន្ត្រៃយ៍[13] ។

5. ការតក់ស្លុត និងស្រងាកចិត្តរបស់មេធាវីការពារក្តី និងរបស់ នួន ជា មិនធ្ងន់ធ្ងរជាងការបដិសេធរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសេចក្តីសម្រេចមិនកោះហៅ ហេង សំរិន ប្រធានសភាជាតិបច្ចុប្បន្ន និងជាយោធាកំពូលមួយរូប នាសម័យកម្ពុជាប្រជាធិបតេយ្យនោះ។ ដូចដែលមេធាវីការពារក្តីបានបញ្ជាក់លម្អិតនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន[14] និងបានបញ្ជាក់ជាថ្មីយ៉ាងច្បាស់ខាងក្រោម[15]។ ហេង សំរិន គឺជាសាក្សីសំខាន់បំផុតនៅក្នុងសំណុំរឿង ០០២/០១។ តាមពិតគាត់ ក៏ជាសាក្សីសំខាន់យ៉ាងជាក់ច្បាស់សម្រាប់សំណុំរឿង ០០២ទាំងអស់[16]។ គាត់មានតួនាទីខ្ពស់ជាមេបញ្ជាការយោធា និងនៅរស់រានមានជីវិតមួយរូបរបស់បក្សកុម្មុយនិស្តកម្ពុជា (“ប.ក.ក”) ដោយមិនបាច់និយាយទៅដល់ឋានៈជាអ្នកដឹកនាំក្នុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហេង សំរិន ទំនងអាចផ្តល់សក្ខីកម្ម ក្នុងនាមជាសាក្សីឃើញហេតុការណ៍ផ្ទាល់ភ្នែក និងសក្ខីកម្មដែលពុំមាននរណាម្នាក់ធ្លាប់បានផ្តល់ឲ្យលើបញ្ហានានា ដោយរួមទាំង ប៉ុន្តែមិនកម្រិតត្រឹមការជម្លៀស

---

[12] មេធាវីការពារក្តីកត់សម្គាល់ថា នៅក្រោមវិធាន ១០៨(៤) អង្គជំនុំជម្រះតុលាការកំពូលតម្រូវឲ្យចេញនូវយ៉ាងហោចណាស់ក៏សម្អាងហេតុសង្ខេប និង សម្អាងហេតុពេញលេញ “នៅពេលបន្ទាប់កាន់តែឆាប់កាន់តែល្អ”។

[13] អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង (អនុវត្ត*ជាធរមាន*ចំពោះកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខអនុលោមតាមវិធាន ១០៤ *ស្ទួន*) រហូតទាល់នឹងការបិទកិច្ចពិភាក្សាដេញដោល ភាគីអាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។

[14] បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១” ២៩ ធ្នូ ២០១៤ (“បណ្តឹងសាទុក្ខ”) កថាខណ្ឌ ៥៩ ដល់ ៧៥។

[15] សូមមើលកថាខណ្ឌ ២៧ ដល់ ៣៥ ខាងក្រោម។

[16] សូមមើលឧទាហរណ៍ដូចជា **E314/6** “បណ្តឹងជំទាស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc Lavergne និង ចៅក្រម យូរ ឧត្តរា” ២៩ សីហា ២០១៤ កថាខណ្ឌ ៣៩ ដល់ ៤០។

ប្រជាជនចេញពីទីក្រុងភ្នំពេញ គោលនយោបាយបក្សកុម្មុយនិស្តកម្ពុជា (ប.ក.ក) ចំពោះអតីតទាហាន និងអ្នករដ្ឋការ លន់ នល់ និងអត្តចរិតរបស់ នួន ជា ដោយសារតែគាត់ស្គាល់ នួន ជា ជាងបីទស្សវត្សរ៍។

6. អ្វីដែលស្ទើរតែគួរឲ្យតក់ស្លុត និងស្រងាកចិត្តដូចទៅនឹងការបដិសេធរបស់អង្គជំនុំជម្រះក្នុងការកោះហៅ ហេង សំរិន គឺការបដិសេធរបស់អង្គជំនុំជម្រះក្នុងការកោះហៅសាក្សី និង Robert Lemkin ផលិតករខ្សែភាពយន្តដ៏គួរឲ្យគោរព ឬសំខាន់ជាងនេះទៅទៀតនោះ ក្នុងការមិនទទួលយកជាបញ្ចូលជាភ័ស្តុតាងនូវកំណត់ហេតុ ("កំណត់ហេតុ") និងប្រតិចារឹកស្ទើរតែទាំងអស់ ("ប្រតិចារឹក") ដែលគាត់បានផ្តល់ជូនអង្គជំនុំជម្រះ គឺគាត់ និង ថេត សម្បត្តិ បានសម្ភាសជាមួយកម្មាភិបាល ប.ក.ក ភូមិភាគពាយ័ព្យ។ ដូចមេធាវីការពារក្តីបានផ្តល់ទឡ្ហីករណ៍នាពេលមុន និងគូសបញ្ជាក់នៅក្នុងចំណុចខាងក្រោមផងដែរ[17] សក្ខីកម្ម កំណត់ហេតុ និងប្រតិចារឹករបស់ Robert Lemkin បង្ហាញនូវព័ត៌មានពិសេសមួយដែលផ្ទុយតែម្តងទៅនឹងសំអាងហេតុសំខាន់ៗបំផុតរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងរចនាសម្ព័ន្ធនៃ ប.ក.ក[18]។

7. យោងតាមហេតុផលទាំងអស់នេះហើយទើប មេធាវីការពារក្តី នួន ជា និយាយឲ្យត្រង់ទៅបានចាត់ទុកសេចក្តីសម្រេចដែលមិនមានសម្អាងហេតុកាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ លើសំណើសុំដែលមិនទាន់បានសម្រេចថាជា "ល្បែងផ្តិនភ្នែកមួយ"។

## ខ. ផលប៉ះពាល់នៃសេចក្តីសម្រេចលើសំណើដែលមិនទាន់សម្រេច ទៅលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីដែលកំពុងរង់ចាំការសម្រេច

8. ជាផលប៉ះពាល់ដោយផ្ទាល់ លើសំណើសុំដាក់ភ័ស្តុតាងបន្ថែម នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ នួន ជា បានជូនដំណឹងទៅអង្គជំនុំជម្រះតុលាការកំពូល តាមរយៈ សារអេឡិចត្រូនិកមួយពី Victor Koppe សហមេធាវីអន្តរជាតិរបស់គាត់ថា នៅពេលនេះ គាត់បានចាត់ទុកលទ្ធផលនៃបណ្តឹងសាទុក្ខរបស់គាត់ជំទាស់សាលក្រមថា "មិនពាក់ព័ន្ធជាមួយគាត់"។ ហើយថែមទាំងបាន "កំពុង

---

[17] សូមមើល កថាខណ្ឌ ២៧ ដល់ ៣៥ខាងក្រោម។

[18] *សូមមើល ឧ.* **F2/4/3/3/4** "សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា ជូនអង្គជំនុំជម្រះតុលាការកំពូលឲ្យស៊ើបអង្កេតបន្ថែមទៅនឹងខ្សែវីដេអូរបស់ផលិតករ ROB LEMKIN និង THET SAMBATH" ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥។

ពិចារណាអំពីជម្រើសនានារបស់គាត់អំពីជំហានឆ្ពោះទៅមុខ រួមទាំងលទ្ធភាពនៃការដកបណ្តឹងសាទុក្ខរបស់គាត់ព្រមគ្នា" និង "ការសម្រេចមិនចូលរួមក្នុងសវនាការ [បណ្តឹងសាទុក្ខ]"[19]។ ដូចគ្នានេះ លោក Koppe ក៏បានគូសបញ្ជាក់ថា គាត់ក៏កំពុងពិចារណាមិនចូលរួមក្នុងសវនាការទាំងនោះផងដែរ ព្រមទាំង "ការដកខ្លួនជាផ្លូវការពីមេធាវីការពារក្តីលើបណ្តឹងសាទុក្ខ"[20]។

9. នៅពេលសវនាការលើបណ្តឹងសាទុក្ខនេះបានចាប់ផ្តើម នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ នួន ជា ត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីថ្លែងការណ៍បឋម។ ដោយបញ្ជាក់ជាថ្មី និងបំភ្លឺលើបញ្ហាកង្វល់ទាំងនេះ, នួន ជា បានគូសបញ្ជាក់ *ក្នុងចំណោមប្រការនានា* ដូចខាងក្រោម៖

> ខ្ញុំទទួលស្គាល់អំពីការឈឺចាប់របស់ប្រជាជនកម្ពុជាយើងមួយចំនួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូចដែលខ្ញុំបាននិយាយជារឿយៗមកហើយ ខ្ញុំមានការសោកស្តាយណាស់ចំពោះទុក្ខវេទនាទាំងនេះ និងសូមទទួលខុសត្រូវខាងសីលធម៌[21]។
>
> ខ្ញុំចូលរួមក្នុងតុលាការនេះដោយជឿជាក់ថា ខ្ញុំទទួលខុសត្រូវចំពោះជនរួមជាតិកម្ពុជាយើង ក្នុងការពន្យល់បំភ្លឺអំពីការពិតដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងដើម្បីបំភ្លឺជនរួមជាតិក្នុងឋានៈខ្ញុំជាអ្នកដឹកនាំទទួលខុសត្រូវមួយរូបរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលនៅរស់រានមានជីវិតអំពីហេតុបច្ច័យ ដែលបក្សយើងបានធ្វើ និងអំពីផលដែលយើងបានទទួល។ ខ្ញុំជឿជាក់ថា នេះជាអ្វីដែលប្រជាជនកម្ពុជាភាគច្រើនចង់យល់ដឹងពីតុលាការនេះផងដែរ[22]។
>
> តែទោះជាយ៉ាងនេះក៏ដោយ ចាប់តាំងពីថ្ងៃដំបូងមក ខ្ញុំចាប់អារម្មណ៍ថា តុលាការនេះ គ្មានបំណងអ្វី ស្វែងរកការពិតឡើយ តែផ្ទុយទៅវិញ តុលាការនេះដូចជាធ្វើទៅតាមបញ្ជារបស់អ្នកកាន់អំណាចមួយក្តាប់តូច និងបក្ស និងតាមការយល់ព្រមពីរដ្ឋាភិបាល តាំងតែពីមុនតុលាការនេះបង្កើតឡើងមកម្ល៉េះ។ ហើយការគិតរបស់ខ្ញុំនេះ គឺត្រឹមត្រូវពិតមែន[23]។
>
> នៅខែ សីហា ឆ្នាំ ២០១៤ បន្ទាប់ពីរយៈពេល ៧ ឆ្នាំ និងការចំណាយអស់ប្រាក់រាប់រយលានដុល្លារ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមកាត់ទោសខ្ញុំអស់មួយជីវិតក្នុងសំណុំរឿង ០០២ ក្បៀស ០១។ វាជា

---

[19] សារអេឡិចត្រូនិកពីសហមេធាវីអន្តរជាតិរបស់ នួន ជា ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ("សារអេឡិចត្រូនិករបស់ Victor Koppe")។

[20] សារអេឡិចត្រូនិករបស់ Victor Koppe។

[21] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១០, ជួរ ២-៥។

[22] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១០, ជួរ ៧-១៣។

[23] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១០, ជួរ ១៣-១៨។

> ការបរាជ័យអាម៉ាស់មួយ[24]។ [...]មេធាវីរបស់ខ្ញុំប្រាប់ខ្ញុំថា របាយការណ៍ស្រាវជ្រាវមួយក្នុងពេលថ្មីៗនេះបាននិយាយដូចគ្នានេះដែរ[25]។

10. បាយការណ៍ស្រាវជ្រាវដែលនួនជាបាននិយាយសំដៅនោះ គឺជាបាយការណ៍ដែលចេញផ្សាយដោយអង្គការដែលរួមទាំងសកលវិទ្យាល័យ Stanford ដែលមានចំណងជើងថា *តើវាជាទស្សនៈសមហេតុផល? ការវិភាគអំពីសំណុំរឿងទីមួយប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម (សំណុំរឿង ០០២/០១)*[26]។ របាយការណ៍នោះបានរៀបរាប់ពីសាលក្រមសំណុំរឿងសាលក្រម ដែល"សរសេរដោយខ្ជីខ្ជារនៅក្រោមបទដ្ឋានទាបរបស់តុលាការព្រហ្មទណ្ឌផ្សេងទៀត [...] មិនគ្រប់លក្ខណៈក្នុងការបំពេញបទដ្ឋានសម្រាប់សេចក្ដីសម្រេចចុងក្រោយដោយសមហេតុផល"[27]។ នៅក្នុងសេចក្ដីថ្លែងការរបស់ខ្លួនជូនអង្គជំនុំជម្រះតុលាការកំពូល នួន ជា បានបង្ហាញអំពីការខកខានជាក់លាក់នៅក្នុងសាលក្រម ព្រមទាំងទស្សនៈជាទូទៅរបស់ខ្លួនក្នុងការដោះស្រាយជាមួយអង្គជំនុំជម្រះតុលាការកំពូលថា

> បើទោះជាមានការខិតខំប្រឹងប្រែងពីមេធាវីរបស់ខ្ញុំអំពីការយល់ដឹងដ៏ពិតប្រាកដអំពីព្រឹត្តិការណ៍ក៏ដោយ ក៏សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមិនយកចិត្តទុកដាក់ និងមិនត្រឹមត្រូវ [28]។ [...]
>
> ចៅក្រមមិនបានគិតដល់ភស្តុតាងដែលបង្ហាញថា ការពិតបក្សមានការបែកបាក់ផ្ទៃក្នុង ហើយដែលភូមិភាគខ្លះធ្វើឡើងតាមទំនើងចិត្ត។ គាត់មិនបានគិតដល់ភស្តុតាងដែលសមាជិកគណៈអចិន្ត្រៃយ៍ខ្លះ និងសមាជិកគណៈមជ្ឈិមបក្ស ដូចជា សោ ភឹម និង រស់ ញឹម ជាដើម បានបង្កើតក្រុមប្រឆាំងនៅក្នុងបក្សដើម្បីព្យាយាមផ្ដួលរំលំរដ្ឋាភិបាលស្របច្បាប់ កម្ពុជាប្រជាធិបតេយ្យ តាមរយៈរដ្ឋាភិបាល តាមរយៈរដ្ឋប្រហារ ដែលរៀបចំបញ្ហាដោយវៀតណាម។ ចៅក្រមមិនបានគិតដល់ភស្តុតាងដែលថារាល់ព្រឹត្តិការណ៍ទាំងអស់នេះ គឺទាក់ទងទៅនឹងមហិច្ឆតាជាយូរមកហើយរបស់វៀតណាមក្នុងការឈ្លានពាន វាតទីលេបទឹកដីកម្ពុជា បំបាត់ពូជ

---

[24] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្ដឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១០, ជួរ ១៩-២២។

[25] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្ដឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១១, ជួរ ២-៣។

[26] David Cohen, Melanie Hyde and Penelope Van Tuyl, *តើវាជាទស្សនៈសមហេតុផល? ការវិភាគអំពីសំណុំរឿងទីមួយប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម (សំណុំរឿង ០០២/០១)*, ២០១៥ 2015, available at: https://handacenter.stanford.edu/report/well-reasoned-opinion-critical-analysis-first-case-against-alleged-senior-leaders-khmer-rouge.

[27] *តើវាជាទស្សនៈសមហេតុផល?* ទំព័រ ៦។

[28] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្ដឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១១, ជួរ ៣-៥។

សាសន៍កម្ពុជា និងបញ្ចូលកម្ពុជាក្នុងសហព័ន្ធឥណ្ឌូចិនដែលមានវៀតណាមជាអ្នកដឹកនាំបញ្ហា[29]។

យើងខ្ញុំមានការអស់សង្ឃឹមពីអ្វីដែលចៅក្រមសាលាដំបូង និងចៅក្រមស៊ើបអង្កេតបានធ្វើកន្លងមក។ តែយើងខ្ញុំនៅតែគិតថានៅមានពន្លឺតូចមួយដែលរឿងរ៉ាវនឹងមានការផ្លាស់ប្តូរនៅចំពោះមុខចៅក្រមអង្គជំនុំជម្រះតុលាការកំពូល[30]។ [...]

នៅក្នុងពេលជំណាលគ្នាក្នុងការចូលរួមក្នុងសវនាការលើកទី២ មេធាវីរបស់ខ្ញុំបានចូលរួមយ៉ាងសកម្មជាមួយអង្គជំនុំជម្រះតុលាការកំពូល។ តាមការពិភាក្សាគ្នាជាមួយខ្ញុំ មេធាវី បានដាក់សំណើជាច្រើនសុំឲ្យទទួលភស្តុតាងថា ភស្តុតាងថ្មីនៅពេលដែលភស្តុតាងទាំងនេះអាចរកបាន មិនធ្លាប់មានពីមុនមក។ ភស្តុតាងថ្មីនេះផ្តល់យ៉ាងលម្អិតអំពីក្បាល និងកន្ទុយក្រពើ ដែលមិនមែនគ្រាន់តែខ្លួនក្រពើនោះទេ ភស្តុតាងបានបញ្ជាក់ថាវៀតណាមធ្វើរដ្ឋប្រហារមួយ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យកាន់អំណាច[31]។ [...]

នៅពេលដែលចាប់ផ្តើម មេធាវីរបស់ខ្ញុំ និងខ្ញុំ ត្រូវបានលើកទឹកចិត្តដោយការឆ្លើយតបរបស់អង្គជំនុំជម្រះតុលាការកំពូលទៅនឹងសំណើសុំភស្តុតាងបន្ថែមរបស់យើងខ្ញុំ។ វាមើលទៅហាក់ដូចជាលើកដំបូងនៅក្នុងតុលាការនេះដែលចៅក្រមដោយរួមទាំងចៅក្រមជាតិផងដែរ មានចេតនាដោះស្រាយ ដោយធ្វើចិត្តឲ្យទូលាយដើម្បីចូលរួមក្នុងការពិភាក្សាពិតប្រាកដមួយអំពីរឿងក្តី។ ជាពិសេស មេធាវីរបស់ខ្ញុំត្រូវបានលើកទឹកចិត្តដោយការយល់ព្រមរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការបើកការស៊ើបអង្កេតលើភស្តុតាង ដែលប្រមូលដោយផលិតករខ្មែរភាពយន្ត ថេត សម្បត្តិ និងលោក រ៉ូបឺត ឡេមគីន។ មេធាវីរបស់ខ្ញុំត្រូវបានលើកទឹកចិត្តផងដែរ នៅពេលអង្គជំនុំជម្រះបានរៀបចំការស្តាប់សក្ខីកម្មរបស់សាក្សីចំនួនបីរូបដែលក្រុមរបស់យើងខ្ញុំបានស្នើឡើងឲ្យមកផ្តល់សក្ខីកម្មសម្រាប់បណ្តឹងសាទុក្ខ។ ដោយសារតែមានការផ្លាស់ប្តូរនេះ មេធាវីរបស់ខ្ញុំបានរៀបចំ និងរង់ចាំយ៉ាងប្រុងប្រយ័ត្ន និងអត់ធ្មត់សម្រាប់សវនាការលើបណ្តឹងសាទុក្ខនេះ[32]។

ការខកចិត្តរបស់ពួកយើងបានកើតឡើងយ៉ាងខ្លាំង នៅពេលដែលអង្គជំនុំជម្រះប្រកាសថាគ្មានសាក្សីណាម្នាក់ដែលយើងខ្ញុំបានស្នើនឹងត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មសម្រាប់បណ្តឹងសាទុក្ខនោះទេ គឺគ្មានលោក ហេង សំរិន, គ្មាន រ៉ូបឺត ឡេមគីន និងគ្មាន ថេត សម្បត្តិ។ មេធាវីរបស់ខ្ញុំបានគិតថា អង្គជំនុំជម្រះយ៉ាងហោចណាស់ក៏កោះហៅលោក ហេង សំរិន ព្រោះអ្វីដែលគាត់ត្រូវនិយាយ គឺមានសារៈសំខាន់ណាស់។ ក៏ប៉ុន្តែការគិតរបស់មេធាវីរបស់ខ្ញុំ គឺខុសស្រឡះ។ នៅចុងបញ្ចប់ លោក លោកស្រីចៅក្រមសម្រេចដដែលដូចទៅនឹងចៅក្រមសាលាដំបូងដែរ នេះគួរឲ្យអស់សង្ឃឹមណាស់។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ក៏បដិសេធផងដែរនូវភស្តុតាងថ្មីដែលយើងខ្ញុំបានស្នើទាំងអស់ ដោយមិនផ្តល់ហេតុផល

[29] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១១, ជួរ ១២-២១។

[30] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១២, ជួរ ៧-១០។

[31] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១៥, ជួរ ៩-១៧។

[32] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១៦, ជួរ ១១-២២។

អ្វីឡើយ។ យើងខ្ញុំលំបាកយល់អំពីសេចក្តីសម្រេចនេះ[33]។

សេចក្តីសម្រេចរបស់អស់លោក លោកស្រីចៅក្រម បានធ្វើឱ្យខ្ញុំបាត់ជំនឿលើលោក លោកស្រីចៅក្រមក្នុងការដោះស្រាយបណ្តឹងសាទុក្ខរបស់ខ្ញុំ។ ខ្ញុំយល់ច្បាស់ណាស់ថា អង្គជំនុំជម្រះតុលាការកំពូលគឺលម្អៀងដូចគ្នា និងខ្លាចដូចគ្នាក្នុងការហៅបុគ្គលមកនៅចំពោះមុខលោក លោកស្រី ក្នុងការស្វែងរកការពិត។ លោក លោកស្រីចៅក្រមបដិសេធផ្តល់ដល់រូបខ្ញុំ សូម្បីតែឱកាសសម្រាប់និយាយបំភ្លឺជូនជនរួមជាតិកម្ពុជាអំពីរឿងរ៉ាវរបស់ខ្ញុំ[34]។ [...]

អាស្រ័យហេតុនេះហើយ បន្ទាប់ពីពិភាក្សាជាមួយខ្ញុំ មេធាវីការពារក្តីអន្តរជាតិរបស់ខ្ញុំគឺលោក វិចទ័រ កូប៉េ មិនចូលរួមក្នុងសវនាការនេះទេ។ ខ្ញុំនឹងចាកចេញពីដំណើរការនេះ នីតិវិធីនេះ នៅពេលដែលខ្ញុំថ្លែងសុន្ទរកថានេះចប់ ហើយខ្ញុំសូមណែនាំសហមេធាវីជាតិរបស់ខ្ញុំ គឺលោក សុន អរុណ សូមមិនឱ្យឆ្លើយតបទៅនឹងសំណួររបស់គ្រប់ភាគី និងមិនឱ្យចូលរួមក្នុងសវនាការនេះតទៅទៀតទេនៅពេលបន្ទាប់ពេលសម្រាក។ យើងខ្ញុំជ្រើសរើសដោយរក្សានូវអំណះអំណាងដែលលើកឡើងនៅក្នុងបណ្តឹងសាទុក្ខរបស់យើងខ្ញុំ។ តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំរក្សាទុកនូវបណ្តឹងសាទុក្ខរបស់ខ្ញុំវិញ ដោយសារតែវាជាកិត្តិយសនៅក្នុងការទទួលខុសត្រូវដែលខ្ញុំបន្តមានក្នុងការបំភ្លឺជនរួមជាតិជាទីគោរពស្នេហារបស់ខ្ញុំ ឱ្យយល់ដឹងអំពីការពិតដែលបានកើតឡើងយ៉ាងពិតប្រាកដ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[35]។

ខ្ញុំសូមទទួចដល់លោក លោកស្រីចៅក្រមឱ្យមានសេចក្តីក្លាហាន និងពិចារណាអំពីការប្តេជ្ញារបស់លោក លោកស្រី ចៅក្រមក្នុងការស្វែងរកការពិត និងយុត្តិធម៌ក្នុងពេលដែលលោក លោកស្រីចៅក្រមសរសេរសាលដីការបស់ខ្លួន។ ប្រជាជនកម្ពុជាមានញាណទស្សនៈច្បាស់ណាស់ និងភ្លឺស្វាងណាស់ គេទាំងឡាយកំពុងរង់ចាំមើលការស្វែងរកការពិត និងយុត្តិធម៌ក្នុងសាលដីការបស់លោក លោកស្រីចៅក្រម។ ប្រជាជនកម្ពុជានឹងមិនមានឱកាសដូចនេះជាថ្មីម្តងទៀតឡើយ[36]

11. មេធាវីអន្តរជាតិ លោក Victor Koppe ពុំបានចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍នៅ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឡើយ ហើយ សុន អរុណ សហមេធាវីជាតិរបស់ នួន ជា បានចាកចេញពី

[33] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១៦, ជួរ ២៤-ទំព័រ ១៧-ជួរ ៨។

[34] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១៧, ជួរ ៨-១៥ (សេចក្តីបញ្ជាក់បន្ថែម)។

[35] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១៧, ជួរ ១៨-ទំព័រ ១៨--ជួរ ៤។

[36] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ១៧-ជួរ ៤-៩។

បន្ទប់សវនាការបន្ទាប់ពីចប់វគ្គដំបូង។ លោក សុន អរុណ ក្រោយមកបានសម្រេចចិត្តចូលក្នុងសវនាការវិញ បន្ទាប់ពីអង្គជំនុំជម្រះបានព្រមានរូបគាត់ និងបានបន្តស្តាប់តាមការណែនាំ របស់ នួន ជា មិនឱ្យឆ្លើយទៅនឹងសំណួរទាំងឡាយ[37]។ បើទោះបីជាលោក អរុណ បានបង្ហាញវត្តមានជាថ្មីក្នុងបន្ទប់សវនាការក៏ដោយ ក៏ចៅក្រម គង់ ស្រ៊ីម ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានប្រកាសថា៖

> ស្របតាមក្របខ័ណ្ឌច្បាប់ជាធរមាន និងដើម្បីធានាថា ការការពារក្តីសមស្របសម្រាប់ជនជាប់ចោទក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្អាកសវនាការបណ្តឹងសាទុក្ខ និងបង្គាប់មកអង្គភាពគាំពារការការពារក្តីឱ្យចាត់តាំងសហមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា និងត្រូវរាយការណ៍មកអង្គជំនុំជម្រះអំពីការចាត់តាំងនេះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន[38]។

12. នៅថ្ងៃបន្ទាប់លោក អរុណ បានដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសេចក្តីសម្រេចដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះតុលាការកំពូល។ លោក អរុណ បានបំភ្លឺអំពីមូលហេតុដែលគាត់អវត្តមានដោយបានពន្យល់ថា គាត់នឹងទៅអង្គុយក្នុងបន្ទប់សវនាការនៅពេលខាងមុខ តាមការបង្ខំរបស់តុលាការ ហើយបានគូសបញ្ជាក់ថា ប៉ុន្តែគាត់នឹងគោរពការណែនាំរបស់កូនក្តីដែលមិនឱ្យឆ្លើយទៅនឹងសំណួររបស់ចៅក្រម និងគ្រប់ភាគី[39]។ បើទោះជាលោកសារអេឡិចត្រូនិចរបស់ Koppe នៅថ្ងៃទី ២៨ តុលា ២០១៥ និងសេចក្តីថ្លែងការរបស់ នួន ជា នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ក៏នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានស្នើលោក Koppe ដាក់សារណាពន្យល់អំពីការមិនចូលរួមសវនាការបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥[40]។ នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ លោក Koppe បានធ្វើដូច្នោះ។ លោក Koppe បានគូសបញ្ជាក់ថា ដោយសារសេចក្តីសម្រេចលើសំណើដែលធ្វើឡើងដោយអង្គជំនុំជម្រះ ធ្វើឱ្យ នួន ជា អស់ជំនឿលើអង្គជំនុំជម្រះ ហើយ នួន ជា បានណែនាំខ្ញុំមិនឱ្យមានវត្តមាននៅក្នុងសវនា

---

[37] *សូមមើល* ឯកសារ **F30/13**, "ការឆ្លើយតបរបស់មេធាវីជាតិលោក សុន អរុណ ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលអំពីហេតុការណ៍ដែលបានកើតឡើងនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥" ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ("សេចក្តីបញ្ជាក់របស់ សុន អរុណ"), កថាខណ្ឌ ៨។

[38] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (សវនាការលើបណ្តឹងសាទុក្ខ, ឯកសារ **F1/4.1**), ទំព័រ ៣៩, ជួរ ៦-១១។

[39] ឯកសារ **F30/13**, សេចក្តីបញ្ជាក់របស់ សុន អរុណ, កថាខណ្ឌ ៧,៩។

[40] ឯកសារ **F30/14**, "សេចក្តីសម្រេចបង្គាប់ឱ្យមេធាវី VICTOR KOPPE ដាក់សារណាទាក់ទងនឹងការខកខានរបស់ខ្លួនក្នុងការចូលរួមសវនាការបណ្តឹងសាទុក្ខ", ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥, ទំព័រ ៤។

ការ។ តែលោក Koppe បានសម្រេចចិត្តមិនលាលែងពីសហមេធាវីអន្តរជាតិ[41] គាត់បានកត់សម្គាល់ថា គាត់ធ្វើដូច្នេះទោះបីជាគាត់ "មានជំនឿយ៉ាងមុតមាំដែលថា សវនាការដ៏ត្រឹមត្រូវយុត្តិធម៌នៅចំពោះមុខអវតក ទាំងអង្គជំនុំជម្រះសាលាដំបូង និងតុលាការកំពូល គឺមិនអាចទៅរួច នឹងបើទោះជា មានជំនឿយ៉ាងមុតមាំថា អវតកតាមពិត និងតែងតែជាត្តុកឈ្លោនកម្លែង"[42]។

## គ. ការចាត់តាំងសហមេធាវីការពារក្តីត្រៀមបម្រុងសម្រាប់ នួន ជា

13. នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ប្រធានផ្នែកគាំពារការការពារក្តី ("DSS") Isaac Endeley បានជូនដំណឹងទៅអង្គជំនុំជម្រះតុលាការកំពូលថា លើកលែងតែមានការកំណត់ពីអង្គជំនុំជម្រះតុលាការកំពូលថាវាជាទំនាស់ផលប្រយោជន៍ ខ្លួនបានមានបំណងតែងតាំងមេធាវីត្រៀមបំរុងគឺលោក កង ឫទ្ធិគិរី ដែលស្ថិតក្នុងចំណោមសហមេធាវីជាតិរបស់ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច ក្នុងសំណុំរឿង ០០១ ជាមេធាវីត្រៀមបម្រុងសម្រាប់លោក នួន ជា[43]។ ហើយពិតណាស់លោក ឫទ្ធិគិរី ជាមេធាវីជាតិមួយចំនួនទំនងជាមានទាំស់ផលប្រយោជន៍នៅក្នុងការការពារក្តី នួន ជា ដូចដែលគាត់បានបញ្ជាក់ដោយខ្លួនឯងផ្ទាល់ជូនអង្គភាពគាំពារការការពារក្តី។ នៅក្នុងចំណោមទំនាស់នោះ ដូចដែលបានលើកឡើងនៅក្នុងសាលក្រមសំណុំរឿង ០០១ និង ០០២/០១ ដូចបានផ្តល់សក្ខីកម្មថា នួន ជា មានការចូលរួមយ៉ាងជិតស្និទ្ធនៅក្នុងស២១[44] ដែលជាការចោទប្រកាន់មួយ នួន ជា បានជំទាស់ជាដាច់ខាត។ នៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ចៅក្រមប្រធាន គង់ ស្រីម បានបង្គាប់ឱ្យលោក Endeley មិនឱ្យធ្វើការតែងតាំងនេះ ដោយយោងទៅលើទំនាស់ផលប្រយោជន៍ដែលអាចមានដែលអាចត្រូវបាន "គេយល់ថាជាការពុំសមស្របសម្រាប់ការការពារផល

[41] ឯកសារ **F30/14/1**, "ការឆ្លើយតបរបស់ **VICTOR KOPPE** ទៅនឹងសំណើរបស់អង្គជំនុំជម្រះតុលាការកំពូលឱ្យពន្យល់ពីមូលហេតុដែលអវត្តមាននៅក្នុងសវនាការលើបណ្តឹងសាទុក្ខ", ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥, កថាខណ្ឌ ៧-៨, ១០។

[42] ឯកសារ **F30/14/1**, "ការឆ្លើយតបរបស់ **VICTOR KOPPE** ទៅនឹងសំណើរបស់អង្គជំនុំជម្រះតុលាការកំពូលឱ្យពន្យល់ពីមូលហេតុដែលអវត្តមាននៅក្នុងសវនាការលើបណ្តឹងសាទុក្ខ" កថាខណ្ឌ ១០។

[43] ឯកសារ **F30/15/1** "បច្ចុប្បន្នភាពទី១ ស្តីពីសេចក្តីសម្រេចណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ការពារក្តី នួន ជា" ២៤ វិច្ឆិកា ២០១៥ កថាខណ្ឌ ៣ ដល់៤។

[44] សំណុំរឿង ***001/18-07-2007/ECCC/TC*** ឯកសារលេខ **E188** "សាលក្រម" ២៦ កក្កដា ២០១០ កថាខណ្ឌ ៩០។ឯកសារលេខ **E313** "សាលក្រមសំណុំរឿង ០០២/០១" កថាខណ្ឌ ៣៤២ ដល់ ៣៤៦។

ប្រយោជន៍របស់ នួន ជា បានពេញលេញឡើយ"[45]។

14. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ លោក Endeley បានតែងតាំងលោក ផាត់ ពៅស៊ាង អតីតសហមេធាវីជាតិរបស់ អៀង ធីរិទ្ធ ជនជាប់ចោទក្នុងសំណុំរឿង ០០២ ដែលទើបបានស្លាប់ ជាមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា[46] និងដែលជាមេធាវីមួយរូបនៅក្នុងប្រទេសដែលទំនងជាមានទំនាស់ផលប្រយោជន៍ក្នុងការការពារក្តីលោក នួន ជា។ យោងតាមលោក ពៅស៊ាង និយាយដោយខ្លួនឯងថា "ពុំមានទំនាស់ផលប្រយោជន៍រវាងអតីតកូនក្តីរបស់គាត់ និងលោក នួន ជា ទេ"[47]។ គួរឱ្យចម្លែក ការវាយតម្លៃរបស់គាត់មិនបានគិតអំពីទំនាស់ដែលត្រូវបានកត់ត្រាជាឯកសារយ៉ាងច្បាស់ក្នុងអំឡុងពេលដែលលោក ពៅស៊ាង ធ្វើជាមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ ក្នុងសំណុំរឿង ០០២។ ទំនាស់ទាំងនេះរួមបញ្ចូលទាំងការស្រែកគំហករបស់អ្នកស្រី អៀង ធីរិទ្ធ ក្នុងពេលស្តាប់ចម្លើយរបស់គាត់លើកដំបូងជាមួយសហចៅក្រមស៊ើបអង្កេត-ដែលលោក ពៅស៊ាង បានចូលរួម និងប្រហែលជាបានផ្តល់ប្រឹក្សាច្បាប់ថា "ខ្ញុំមិនដែលសម្លាប់នរណាម្នាក់នោះទេ, តើនរណាជាអ្នកប្រាប់លោក? គឺ នួន ជា ជាឃាតករសកល។ លោកចៅក្រមនឹងឃើញ!"[48]។ ឧប្បត្តិហេតុធ្ងន់ធ្ងរមួយចំនួនទៀតក៏បានកើតមានឡើងនៅក្នុងមន្ទីរឃុំឃាំង ដូចដែលត្រូវបានបញ្ជាក់លម្អិតយ៉ាងវែងក្នុងរបាយការណ៍សម្ងាត់[49]។

15. បន្ទាប់ពីពេលចាត់តាំងលោក ពៅ ស៊ាង ជាសហមេធាវីត្រៀមបម្រុងសម្រាប់ការពារក្តី នួន ជា នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថាសវនាការលើបណ្តឹង

---

[45]ឯកសារ **F30/15/1/1**, ការឆ្លើយតបទៅនឹងអនុស្សរណៈរបស់អង្គភាពគាំពារការការពារក្តីចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៥, ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥, ទំព័រ ៣។

[46]ឯកសារ **F30/15/2**, "បច្ចុប្បន្នភាពទី២ស្តីពីសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ការពារក្តី នួន ជា", ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ("ការចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា"), កថាខណ្ឌ ៤។

[47] ឯកសារ **F30/15/2**, ការចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា, កថាខណ្ឌ ៣។

[48]ឯកសារ **E3/38**, "កំណត់ហេតុនៃការសួរចម្លើយ អៀង ធីរិទ្ធ",ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧, ERN 00418012 (សេចក្តីបញ្ជាក់បន្ថែម, ចំណារ និងឃ្លាជាភាសាខ្មែរត្រូវបានលុបចោល)។

[49] *សូមមើល* ឯកសារ **D139/2**, "សេចក្តីបំភ្លឺស្តីពីឧប្បត្តិហេតុដែលកើតមានឡើងនៅមន្ទីរឃុំឃាំង អ.វ.ត.ក", ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩។ ឯកសារ **B37/5**, "សេចក្តីរាយការណ៍ស្តីអំពីជនជាប់ចោទឈ្មោះ អៀង ធីរិទ្ធ មានសកម្មភាពមិនប្រក្រតី និងអសីលធម៌នៅក្នុងមន្ទីរឃុំឃាំង" ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩។

សាទុក្ខត្រូវបន្តនៅថ្ងៃទី ១៦ ដល់ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដោយយកថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ជាថ្ងៃបម្រុង[50]។ ដោយសារតែលោក ពៅស៊ាង មិនទាន់យល់ដឹងអំពីសំណុំរឿងរបស់ នួន ជា អង្គជំនុំជម្រះបានបញ្ជាក់ថា សវនាការលើបណ្ដឹងសាទុក្ខពុំអាចបន្តភ្លាមៗបានឡើយ ដោយសារតម្រូវការចាំបាច់ក្នុងការធានាឲ្យបានថា សហមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា ត្រូវ "មានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាសំណុំរឿងនេះជាមុន"[51]។

## ឃ. ទណ្ឌកម្មដែលបានដាក់លើមេធាវីការពារក្ដី

16. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្ដីសម្រេចលើការប្រព្រឹត្តរបស់មេធាវីការពារក្ដីនៅក្នុងសវនាការលើបណ្ដឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ("សេចក្ដីសម្រេចដាក់ទណ្ឌកម្មមេធាវីការពារក្ដី")[52]។ អង្គជំនុំជម្រះកំណត់ថា ការប្រព្រឹត្តរបស់សហមេធាវីការពារក្ដីអន្តរជាតិ "ពុំបានរំលោភច្បាស់ជាក់លាក់ណាមួយ ឬក៏បង្គាប់របស់តុលាការ"[53] ការប្រព្រឹត្តរបស់មេធាវីជាតិគឺពិតជាបានរំលោភដល់វិធាន ៣៨ និងអាចរំលោភផងដែរវិធាន ៣៥[54]។ នៅចុងបញ្ចប់ អង្គជំនុំជម្រះបានបង្គាប់ទៅ DSS "នូវសេចក្ដីសម្រេចបច្ចុប្បន្ននេះស្ដីអំពី [...] លែងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខតទៅទៀត" និង "កំណត់ពីការចំណាយដែលជាបន្ទុករបស់ អវតក ទៅលើសេវាកម្មផ្នែកច្បាប់របស់សហមេធាវីជាតិ និងអន្តរជាតិនៅក្នុងសំណុំរឿង ០០២/០១"[55]។ មេធាវីការពារក្ដីកត់សម្គាល់ថា វិធានការចុងក្រោយនេះគឺ គួរឲ្យអស់សំណើចខ្លាំងណាស់ ដោយសារតែយ៉ាងហោចណាស់មានចៅក្រមអង្គជំនុំជម្រះតុលាការកំពូលមួយរូបត្រូវបានមើលឃើញកំពុងតែដេកនៅក្នុងអំឡុងពេល

---

[50] ឯកសារ **F30/17**, "ដីកាកំណត់កាលបរិច្ឆេទបន្តសវនាការលើបណ្ដឹងសាទុក្ខ", ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥, ទំព័រ ៤ ("ដីកាកំណត់ពេលបន្តសវនាការបណ្ដឹងសាទុក្ខ")។

[51] ឯកសារ **F30/17**, ដីកាកំណត់ពេលបន្តសវនាការបណ្ដឹងសាទុក្ខ, ទំព័រ ៣។

[52] ឯកសារ **F30/18** "សេចក្ដីសម្រេចស្ដីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្ដី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្ដឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥" ២៧ មករា ២០១៦ ("សេចក្ដីសម្រេចដាក់ទណ្ឌកម្មមេធាវីការពារក្ដី")

[53] ឯកសារ **F30/18** "សេចក្ដីសម្រេចដាក់ទណ្ឌកម្មមេធាវីការពារក្ដី" កថាខណ្ឌ ២៨។

[54] ឯកសារ **F30/18** "សេចក្ដីសម្រេចដាក់ទណ្ឌកម្មមេធាវីការពារក្ដី" កថាខណ្ឌ ៣២ ដល់ ៣៣។

[55] ឯកសារ **F30/18** "សេចក្ដីសម្រេចដាក់ទណ្ឌកម្មមេធាវីការពារក្ដី" កថាខណ្ឌ ៣៥។

សវនាការលើបណ្តឹងសាទុក្ខ និងថាមានចៅក្រមមួយរូបហាក់បីដូចជាមានការយល់ដឹងលម្អិតអំពីសំណុំរឿង ដោយមិនបាច់លើកអំពីប្រវត្តិសាស្ត្រប្រទេសរបស់គាត់ បើទោះជាខ្លួនមានរយៈពេលរាប់ឆ្នាំដើម្បីពិនិត្យក៏ដោយ ដូចដែលបានឃើញនៅក្នុងពេលសួរដេញដោលសាក្សីនៅអំឡុងពេលសវនាការថា: “នៅក្នុងអំឡុងពេលរបបប៉ុលពត ពុំមានវិទ្យុផ្សាយសម្រាប់ប្រើដើម្បីផ្សព្វផ្សាយ និងអូសទាញប្រជាជន។ទេ។ ចុះហេតុអ្វីអ្នកអាចអូសទាញប្រជាជនឲ្យចូលរួមកាន់តែច្រើន?”[56]។ ជាងនេះទៅទៀត វិធានការនេះបានបង្ហាញថា ការធ្វើមិនដឹងមិនលឺរបស់អង្គជំនុំជម្រះដែលថាតាមពិតទៅមេធាវីត្រូវបានចំណាយតែទៅលើតែសំណុំរឿងមួយប៉ណ្ណោះ តែតាមពិតទៅមេធាវីការពារក្តីគឺមានភាពមមាញឹកជាប្រចាំទៅនឹងការងារសម្រាប់សំណុំរឿង ០០២/០១ និង ០០២/០២។ នេះមិនគ្រាន់តែថា មេធាវីការពារក្តីត្រូវបានទូទាត់មិនគ្រប់គ្រាន់ទេ និងធ្វើការច្រើននោះទេ វាក៏មានន័យផងដែរថា នៅពេលខ្លួនមិនបានធ្វើសម្រាប់បណ្តឹងសាទុក្ខ គឺត្រូវបានប្រើប្រាស់ពេញម៉ោងសម្រាប់ការរៀបចំសវនាការ។

## ង. សំណើបន្ទាន់

17. ដូចដែលបានកត់សម្គាល់ខាងលើ មេធាវីការពារក្តី និង នួន ជា មានភាពជឿងឆ្ងល់យ៉ាងខ្លាំង ទាក់ទងនឹងរឿងដ៏ចម្លែករបស់ អវតក និងអំពីដំណើរការបណ្តឹងឧទ្ធរណ៍ ដែលនាំឲ្យខ្លួនមានបំណងចូលរួមដោយមិនពេញលេញនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍។ បើទោះជាយ៉ាងនេះក៏ដោយ ក៏មេធាវីការពារក្តីគិតថា វាចាំបាច់ណាស់ដើម្បីដាក់សំណើនេះ បើទោះជាវាហាក់បីដូចជាឥតប្រយោជន៍ក៏ដោយ។ ខ្លួនធ្វើដូចនេះគឺដោយសារតែយល់ឃើញថា ភស្តុតាងដែលមិនបានគិតគូរដោយសេចក្តីសម្រេចមិនសមហេតុផលលើសំណើដោយសមហេតុផលនេះ គឺមានសារៈសំខាន់សម្រាប់សាធារណៈជន និងកត់ត្រាទុកថា មេធាវីការពារក្តីត្រូវតែព្យាយាមគ្រប់មធ្យោបាយទាំងអស់ដើម្បីធានាថា ភស្តុតាងសំខាន់បែបនេះគឺមិនត្រូវបានកប់ចោល។

18. នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលមិនបានចេញសេចក្តីសម្រេចរបស់ខ្លួនក្នុងការដាក់ទណ្ឌកម្មមេធាវីការពារក្តីក្នុងរយៈពេលពីរខែចំពោះការចោទប្រកាន់ថាបានប្រមាថនោះ រហូតកាលបរិច្ឆេទនៃសំណើបន្ទាន់ អង្គជំនុំជម្រះពុំបានផ្តល់សំអាងហេតុចំពោះសេចក្តីសម្រេចលើសំណើសុំដាក់ភ័ស្តុតាង ឬបញ្ជាក់ថា ការផ្តល់សំអាងហេតុអាចនឹងមាននៅពេលណាឡើយ។ មកដល់ពេល

---

[56] ប្រតិចារិក ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៥ (ទាត់ ធឿន, F1/3.1 ) ទំព័រ ១២០ បន្ទាត់ ៧ ដល់៩។

នេះគឺមានរយៈពេលជាងបីខែហើយ ចាប់តាំងពីពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញ សេចក្ដីសម្រេចសលើសំណើដែលមិនទាន់បានសម្រេច និងមានរយៈពេល១៦ខែ ចាប់តាំងពីមេធាវីការពារក្ដីបានដាក់សំណើលើកទី១[57]ក្នុងចំណោមសំណើជាច្រើន ដែលបានលើកឡើងនៅក្នុង សេចក្ដីសម្រេចលើសំណើ ដែលមិនទាន់បានសម្រេច។

19. យោងករណីដូចលើកឡើងខាងលើ នៅពេលនេះមេធាវីការពារក្ដីសូមដាក់សំណើបន្ទាន់សុំឱ្យ អង្គជំនុំជម្រះតុលាការកំពូល៖

(ក) ពិចារណាសេចក្ដីសម្រេចរបស់ខ្លួនឡើងវិញ៖

(i) ក្នុងការមិនកោះហៅសាក្សី ហេង សំរិន និង Robert Lemkin, និង

(ii) ក្នុងការមិនទទួលយកជាភ័ស្ដុតាងនូវកំណត់សម្គាល់ និងប្រតិចារឹករបស់លោក Lemkin ឬជាជម្រើសមួយទៀត

(ខ) ផ្ដល់សំអាងហេតុពេញលេញជាបន្ទាន់ចំពោះសេចក្ដីសម្រេចលើសំណើសុំដាក់ភ័ស្ដុតាង មុនពេលបន្ដសវនាការបណ្ដឹងសាទុក្ខ

20. នួន ជា បានណែនាំមេធាវីការពារក្ដីថា ក្នុងករណីដែលសំណើណាមួយត្រូវបានឯកភាព នៅពេល នោះមេធាវីការពារក្ដីអាចពិចារណាអំពីការចូលរួមពេញលេញក្នុងសវនាការបណ្ដឹងសាទុក្ខ។

## III. បរិបទដែលសំណើសុំសាក្សី និងភស្ដុតាងបន្ថែមទាំងនេះត្រូវបានធ្វើឡើង

## ក. ផលប៉ះពាល់ពី "បាបពីកំណើត"

### *(i) នៅដំណាក់កាលមុនសវនាការ*

21. មេធាវីការពារក្ដីពុំបានដាក់សំណើសុំភ័ស្ដុតាង និងសាក្សីបន្ថែមយ៉ាងច្រើននោះ ដោយគ្រាន់តែដើម្បី ធ្វើយ៉ាងណាឱ្យមេធាវីការពារក្ដីបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវអ្វីដែលអង្គជំនុំជម្រះតុលាការកំពូលបាន

---

[57] **F2** "សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្ដុតាងបន្ថែមទាក់ទងនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១" ១ កញ្ញា ២០១៤ ("សំណើលើកទីមួយសុំភស្ដុតាងបន្ថែម")។

ពិពណ៌នាថាជា “សិទ្ធិនីតិវិធីដែលមាន” ចំពោះ នួន ជា[58]។ មេធាវីការពារក្តីក៏ពុំបានដាក់សំណើសុំភ័ស្តុតាង និងសាក្សីបន្ថែមយ៉ាងច្រើននោះដើម្បីបង្កើតជាផ្នែកមួយនៃផែនការរៀចរេរធ្វើឱ្យអង្គជំនុំជម្រះភាន់ច្រឡំ ព្រមទាំងបង្អាក់ និងពន្យារកិច្ចដំណើរការនីតិវិធីដូចអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងដដែលៗនោះក៏ទេដែរ[59]។ មេធាវីការពារក្តីបានដាក់សំណើសុំភ័ស្តុតាង និងសាក្សីបន្ថែមយ៉ាងច្រើននោះដោយសារវាកើតចេញពីលទ្ធផលនៃសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលមានកំហុសតាំងនៅមុនពេលចូលក្នុងសំណុំរឿង ០០២/០១ ហើយដែលទទួលយកជាបន្តបន្ទាប់ដោយអង្គជំនុំជម្រះសាលាដំបូង។ សេចក្តីសម្រេចដែលមានកំហុសនេះស្តែងចេញច្បាស់នូវកំហុសនីតិវិធីយ៉ាងសន្ធឹកសន្ធាប់ ផ្ទុយយ៉ាងជាក់ស្តែងទៅនឹងច្បាប់ ដោយសារសេចក្តីសម្រេចនេះបានបង្ហាញការវិភាគរបស់មេធាវីការពារក្តីនៅក្នុងសារណាបណ្តឹងសាទុក្ខលើអង្គសេចក្តីអំពីកំហុសនីតិវិធីផ្សេងទៀត ដែលបានប្រព្រឹត្តឡើងនៅក្នុងការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១។ សេចក្តីសម្រេចនេះដែលជា “បាបពីកំណើត” គឺជា*ការដកហូតសិទ្ធិទាំងស្រុងរបស់មេធាវីការពារក្តីលើគ្រប់ទិដ្ឋភាពក្នុងការធ្វើការស៊ើបអង្កេតដោយខ្លួនឯង និងបន្តមិនឱ្យស៊ើបអង្កេតនៅគ្រប់ទិដ្ឋភាពនៅមុនពេលជំនុំជម្រះ*។ ដូចដែលមេធាវីការពារក្តីបានអះអាងនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនថាប្រព័ន្ធច្បាប់ស៊ីវិល និងខំមិនឡូ<u>ទាំងពីរ</u>ទទួលស្គាល់ថា ជនជាប់ចោទមានតួនាទីសកម្មនៅក្នុងការស៊ើបអង្កេតដោយ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល អនុញ្ញាតឱ្យមេធាវីការពារក្តីមានវត្តមាន ចូលរួម និងស្តាប់ចម្លើយសាក្សីនៅក្នុងអំឡុងពេលសម្ភាសន៍ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត

---

[58] *សូមមើល* អ.វ.ត.ក *ផែនការបញ្ចប់ អ.វ.ត.ក (វិសោធនកម្មលើកទី៧)* ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ អាចរកមើលបានតាមរយៈគេហទំព័រ http://www.eccc.gov.kh/sites/default/ files/ECCC_Completion_Plan_Rev_7.pdf កថាខណ្ឌ៤៥។ អ.វ.ត.ក *ផែនការបញ្ចប់ អ.វ.ត.ក (វិសោធនកម្មលើកទី៦)* ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ អាចរកមើលបានតាមរយៈគេហទំព័រ http://www.eccc.gov.kh/sites/default/files/ECCC_Completion_Plan_Rev_6.pdf កថាខណ្ឌ៤០។

[59] *សូមមើល ឧ.* ឯកសារ **F2/8/5** “ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៦របស់ នួន ជា សុំឱ្យមានការពិចារណា និងទទួលយកភ័ស្តុតាងបន្ថែមទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១” ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៥ កថាខណ្ឌ ៣, ៤, ៧, ១៣, ១៨, ២១, ២៦, ២៧, ៣៥, ៣៩, ៤១, ៥០, ៥៦, ៥៩, ៦១, ៨២, ៨៣, ៩០, ៩២, ៩៧ និង ១០៥។ ឯកសារ F2/8/5 “ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី៤របស់ នួន ជា ស្នើសុំឱ្យពិចារណា និងទទួលយកភ័ស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១” ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ៥។ ឯកសារ **F2/7/1** “ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីប្រាំរបស់ នួន ជា សុំឱ្យពិចារណា និងទទួលយកភ័ស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១” ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ៣។

នៅមុនអំឡុងពេលសវនាការ។ ហើយនៅក្នុងប្រព័ន្ធខំមិនឡូ អនុញ្ញាតឲ្យជនជាប់ចោទធ្វើការស៊ើបអង្កេតដោយឯករាជ្យខ្លួនឯង[60]។

22. ការហាមឃាត់នេះមិនឲ្យមេធាវីការពារក្តីចូលរួមក្នុងការស៊ើបអង្កេត ចាប់ផ្តើមពីលិខិតពីសហចៅក្រមស៊ើបអង្កេត បានផ្ញើជូនមេធាវីការពារក្តី ដោយហាមឃាត់ជនជាប់ចោទទាំងអស់នៅក្នុងសំណុំរឿង ០០២ មិនឲ្យអនុវត្តសិទ្ធិជាសកលរបស់ខ្លួនក្នុងការស៊ើបអង្កេតលើការចោទប្រកាន់តាមបើទោះតាមច្បាប់ស៊ីវិល ឬខមិនឡូ[61]។ ដូច្នេះ មេធាវីការពារក្តីរងការគម្រាមកំហែងក្រោមទណ្ឌកម្មវិន័យ និងបណ្តឹងអាជ្ញាចំពោះការបំពេញកិច្ចស៊ើបសួរណាមួយដោយខ្លួនឯង ហើយមេធាវីការពារក្តីក៏ត្រូវបានហាមឃាត់មិនឲ្យមានវត្តមាន និងចូលរួមនៅក្នុងការស្តាប់ចម្លើយដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតទៀតផង។ សហចៅក្រមស៊ើបអង្កេត Lemonde បានបញ្ជាក់ថា ជនជាប់ចោទមានសិទ្ធិតទល់នឹងភស្តុតាងប្រឆាំងនឹងខ្លួន សិទ្ធិនេះអាចត្រូវបានប្រើប្រាស់ "នៅដំណាក់កាលសវនាការ [ដោយពិនិត្យ] *សាក្សីទាមួយ*ប្រឆាំងនឹងខ្លួនហើយដែលខ្លួនមិនបានតទល់នៅក្នុងអំឡុងពេលស៊ើបអង្កេត"[62]។ ខ្លាំងជាងនេះទៅទៀតនោះ សហចៅក្រមស៊ើបអង្កេតបានច្រានចោលភ្លាមៗស្ទើរតែគ្រប់សំណើទាំងអស់ចំនួន ១៩ សុំឲ្យបំពេញកិច្ចស៊ើបសួរដែលមេធាវីការពារក្តីបានដាក់ដើម្បីស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរឲ្យបានពេញលេញលើចំណុចស៊ើបសួរសារធាតុ ពាក់ព័ន្ធនឹងកិច្ចការពារក្តីរបស់គាត់[63] ដោយបានសម្រេចមិនយក ចិត្តទុកដាក់ ឬក៏បដិសេធដោយមានហេតុផលតិចតួចបំផុត[64]។

23. អាស្រ័យហេតុនេះ មេធាវីការពារក្តីបានដាក់សំណើសុំម្តង ហើយម្តងទៀតជូនទៅសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូង ដោយបានស្នើសុំឲ្យជួសជុលកំហុសនេះ ហើយបានគូស

---

[60] ឯកសារ **F16** បណ្តឹងសាទុក្ខ កថាខណ្ឌ ៣២។

[61] **A110/I** អនុស្សារណៈពីការិយាល័យសហចៅក្រមស៊ើបអង្កេត "ការឆ្លើយតបទៅនឹងលិខិតរបស់លោកចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ ស្នើពីការស៊ើបអង្កេត" ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨។ សូមមើលផងដែរ **F16** បណ្តឹងសាទុក្ខ កថាខណ្ឌ ៣១ ដល់ ៣២។។

[62] **A110/I** អនុស្សារណៈពីការិយាល័យសហចៅក្រមស៊ើបអង្កេត "ការឆ្លើយតបទៅនឹងលិខិតរបស់លោកចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ ស្នើពីការស៊ើបអង្កេត" ទំព័រ២។ មើលផងដែរឯកសារ **F16** បណ្តឹងសាទុក្ខ កថាខណ្ឌ ៣១។

[63] *សូមមើល* ឯកសារ **F16** បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៦។

[64] *សូមមើល* ឯកសារ **F16** បណ្តឹងសាទុក្ខ កថាខណ្ឌ ៣២-៣៣, ៣៦, ៣៩។

បញ្ជាក់ព្យសនកម្មពីកំហុសទៅមិនត្រឹមតែទៅលើសិទ្ធិរបស់ នួន ជា ក្នុងការបង្ហាញការការពារក្តីតទល់នឹងភ័ស្តុតាងដាក់បន្ទុក ប៉ុន្តែថែមទាំងសិទ្ធិទទួលបានសមភាពរវាងគូភាគីក្តី។ ផ្ទុយពី នួន ជា ដែលត្រូវបានហាមឃាត់មិនឲ្យធ្វើការស៊ើបអង្កេត សហព្រះរាជអាជ្ញាបែជាធ្វើការស៊ើបអង្កេតលើការចោទប្រកាន់ដោយសេរីនៅពេញមួយឆ្នាំ ហើយបានសរសេរនូវសារណាយ៉ាងវែងជូនសហចៅក្រមស៊ើបអង្កេត។ ដោយរួមមានដូចជា ដីការបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនៅក្នុងអំឡុងពេលស៊ើបអង្កេត និងដីកាសន្និដ្ឋានស្ថាពរនៅពេលចុងបញ្ចប់ការស៊ើបអង្កេត។ តាមរយៈការរាប់របស់មេធាវីការពារក្តី សារណាទាំងអស់នោះមានរហូតដល់ជាង *មួយពាន់ទំព័រ* ឯណោះ។

24. សហព្រះរាជអាជ្ញាពេញចិត្តដែលថា ការទាមទាររបស់មេធាវីការពារក្តីមិនត្រូវបានរាប់បញ្ចូលនៅក្នុងការស៊ើបអង្កេតគឺត្រូវបានបដិសេធដោយសំណើសុំឲ្យស៊ើបអង្កេតជាច្រើនទាំងនេះ។ ហើយក៏រីករាយដែលថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានពិនិត្យដោយអង្គបុរេជំនុំជម្រះ។ វាគួរឲ្យអស់សំណើចដែល សហព្រះរាជអាជ្ញាក្នុងពេលនេះធ្វើការជំទាស់ទៅនឹងមេធាវីការពារក្តីដែលថា ខ្លួនមិនបានព្យាយាមឲ្យអស់សមត្ថភាពក្នុងកាលៈទេសៈលំបាកដើម្បីចូលរួមក្នុងការស៊ើបអង្កេត។ ប្រសិនបើមេធាវីការពារក្តីមិនបានធ្វើដូច្នោះ ខ្លួននឹងពិតជាត្រូវបានស្តីបន្ទោសថាខ្វះការខិតខំប្រឹងប្រែងសមហេតុផល។ វាពិតណាស់ហើយថា ឱកាសក្នុងការធ្វើសំណើឲ្យស៊ើបអង្កេតគឺមិនដូចគ្នាទៅនឹងការស៊ើបអង្កេតដោយឯករាជ និងប្រកបដោយសារធាតុនោះទេ។ វាពិតណាស់ហើយថា សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការស៊ើបអង្កេតលើបទចោទប្រឆាំងនឹងខ្លួន គឺមិនត្រូវបានប្រើប្រាស់ដោយជនជាប់ចោទ ក្នុងការស្នើសុំ*ឲ្យបុគ្គលណាម្នាក់ឲ្យប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន*ដើម្បីស៊ើបអង្កេតជំនួសខ្លួននោះទេ។ ជាការពិតណាស់សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលសហព្រះរាជអាជ្ញាយោងទៅលើនោះ គឺមិនបានគ្រប់ដណ្តប់លើសារធាតុរបស់សំណើទាំងអស់នោះទេ។ សេចក្តីសម្រេចនេះគ្រាន់តែលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តនៅវង្វង់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការគ្រប់គ្រងការស៊ើបអង្កេត*របស់ខ្លួន*[65]។

### *(ii) ដំណាក់កាលសវនាការ*

[65] សូមមើលជាទូទៅ F17/1 "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១" ២៤ មេសា ២០១៥ កថាខណ្ឌ ៧៩។

25. កិច្ចស៊ើបសួរបានទទួលរងនូវអានុភាពប៉ះពាល់យ៉ាងធំធេងដោយសារផលវិបាក ទើបនៅទីបំផុត មេធាវីការពារក្តី បានជំទាស់ (មិនបានជោគជ័យ) នឹងធម្មានុរូបនៃសំណុំរឿងទាំងមូល និងស្នើសុំឲ្យផ្អាកកិច្ចដំណើរការនីតិវិធី[66]។ ដូចនឹងសហចៅក្រមស៊ើបអង្កេតដែរ នៅចំពោះមុខខ្លួន ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងបានបិទលទ្ធភាពយ៉ាងមានប្រសិទ្ធភាព មិនឲ្យមេធាវីការពារក្តីចូលរួមនៅក្នុងការបង្កើតមូលដ្ឋានភ័ស្តុតាងសម្រាប់ការជំនុំជម្រះ ពោលគឺបានច្រានចោលស្ទើរតែរាល់សំណើសុំសាក្សីរបស់មេធាវីការពារក្តី រួមទាំងសំណើសុំសាក្សីសំខាន់ ដែលនឹងយកមកពិភាក្សាបន្ថែមនៅក្នុងចំណុចខាងក្រោម[67]។ សេចក្តីសម្រេចទាំងនេះនាំឲ្យអង្គជំនុំជម្រះសាលាដំបូងសរសេរសាលក្រម ដោយផ្អែកលើមូលដ្ឋានភ័ស្តុតាងតែម្ខាង និងមានកំហុសយ៉ាងខ្លាំង ដែលជាហេតុរំលោភលើការធានានូវសិទ្ធិជាសារវ័ន្តមួយចំនួនរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងដំណើរការនេះរហូតមក។

26. ដូច្នេះ សំណើសុំសាក្សី និងភ័ស្តុតាងបន្ថែមរបស់មេធាវីការពារក្តីអាចត្រូវបានមើលឃើញមួយផ្នែកថាជាប្រតិកម្មទៅនឹងការវិវឌ្ឍថ្មីៗនៅក្នុងការស៊ើបអង្កេត និងការជំនុំជម្រះក្នុងសំណុំរឿង 00២/0១ និងទៅនឹងសាលក្រមមិនគ្រប់ជ្រុងជ្រោយដែលនាំឲ្យមានលទ្ធផលបែបនេះ។ មេធាវីការពារក្តីបានដាក់សំណើសុំរបស់ខ្លួន និងជាពិសេសសំណើសុំស្តាប់សាក្សីសំខាន់របស់ខ្លួននៅក្នុងបណ្តឹងសាទុក្ខ ដោយសារទទួលស្គាល់នូវអំណាចធំធេងរបស់អង្គជំនុំជម្រះតុលាការកំពូលអនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក "ដោយខ្លួនអាចបើកការពិនិត្យលើភ័ស្តុតាង និងស្វែងរកភ័ស្តុតាងថ្មីដើម្បីសម្រេចលើបញ្ហាទាំងនេះ" មេធាវីការពារក្តីដាក់សំណើនេះដោយមានក្តីរំពឹងថា អង្គជំនុំជម្រះតុលាការកំពូលអាចប្រកាន់យកវិធានការស្មើភាព និង ត្រឹមត្រូវជាងបើទោះជាខ្លួនកត់សម្គាល់ថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះនៅលើសំណើដែលមិនទាន់សម្រេច វាជាសញ្ញាមួយដែលថា ការរំពឹងនេះវានឹងខុសស្រឡះ ដោយសារតែអង្គជំនុំជម្រះបានបដិសេធចោលសំណើទាំងពីររបស់មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះបើការស៊ើបអង្កេតទៅលើ

[66] ឯកសារ **E51/3** "អញ្ញត្រកម្មរួមបញ្ចូលគ្នា" ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៧៣។ *សូមមើលផងដែរ* ឯកសារ **F16** បណ្តឹងសាទុក្ខ កថាខណ្ឌ ៣៩។

[67] *សូមមើល* កថាខណ្ឌ ២៦ ដល់ ៤៦ ខាងក្រោម។

ព្រឹត្តិការណ៍ដែលបានលើកឡើងនៅក្នុងសក្ខីកម្ម សំ សិទ្ធី[68] និងបានហាមឃាត់មេធាវីការពារក្ដីក្នុងការស៊ើបអង្កេតដោយខ្លួនឯង[69]។

## ខ. ផលប៉ះពាល់ពីការជ្រៀតជ្រែកខាងនយោបាយ

27. សំណើសុំសាក្សី និងភស្តុតាងបន្ថែមរបស់មេធាវីការពារក្ដីត្រូវបានធ្វើឡើង ក៏ដោយសារផលនៃការជ្រៀតជ្រែកខាងនយោបាយយ៉ាងខ្លាំង ដែលសាលាក្ដីនេះមានការពាក់ព័ន្ធចាក់ស្រេះដោយជៀសមិនរួច។ ឧទាហរណ៍ ត្រឹមតែប៉ុន្មានថ្ងៃក្រោយការប្រកាសសាលក្រមនេះ ថេត សម្បត្តិ ផលិតករខ្សែភាពយន្តរឿង*សត្រូវប្រជាជនឯង* ដែលបច្ចុប្បន្នកំពុងនិរទេសខ្លួនរស់នៅក្នុងសហរដ្ឋអាមេរិក បានផ្ដល់កិច្ចសម្ភាសន៍មួយជូនដល់វិទ្យុសំឡេងសហរដ្ឋអាមេរិក។ លោក ថេត សម្បត្តិ បានពិពណ៌នាអំពីសាក្សីមួយចំនួនដែលបានប្រាប់គាត់ថា "អ្នកដែលផ្ដួចផ្ដើមគំនិតទៅសម្លាប់ទាហាន លន់ នល់ មិនមែន នួន ជា ទេ... *មនុស្សជាច្រើនដែលនៅស្ថិតក្នុងរដ្ឋាភិបាលបានផ្ដួចផ្ដើមគំនិតសម្លាប់ប្រជាជន* ហើយពួកគេនៅរស់រានមានជីវិតនៅឡើយ"[70] ប៉ុន្តែសាក្សីទាំងនេះខ្លាចក្នុងការមកផ្ដល់សក្ខីកម្មនៅសាលាក្ដី ពីព្រោះពួកគេបាននិយាយថា "អញ្ចឹងបើខ្ញុំនិយាយទៅ*គេមិនសម្លាប់ខ្ញុំ*"[71]។ ភស្តុតាងនេះនឹងត្រូវបានដាក់បញ្ចូលដោយផ្ទាល់ទៅលើការរកឃើញក្នុងសាលក្រម ដែលថា នួន ជា ទទួលខុសត្រូវព្រហ្មទណ្ឌទៅលើការសម្លាប់ទាហាន និងមន្ត្រី សាធារណៈរដ្ឋ ដូចដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១។ លោក សម្បត្តិ ក៏បានពន្យល់ផងដែរថា ខ្សែភាពយន្តឯកសារទីពីរដែលនឹងចេញផ្សាយក្នុងពេលឆាប់ៗខាងមុខដោយមាន Robert Lemkin ជាផលិតករ

---

[68] សំ សិទ្ធី ជាសាក្សីមួយក្នុងចំណោមសាក្សីទាំងបីរបស់មេធាវីការពារក្ដីដែលអង្គជំនុំជម្រះតុលាការកំពូលយល់ព្រមកោះហៅ (សូមមើល កថាខណ្ឌ២)។ មេធាវីការពារក្ដីស្នើ សក្ខីកម្មគាត់ព្រោះព័ត៌មានដែលគាត់ផ្ដល់ជូនគឺអាចសាកល្បងភាពអាចជឿជាក់បាន ដោយពិចារណាអំពីភាពពាក់ព័ន្ធសំខាន់ នៅក្នុងសាលក្រម ហើយដែលគាត់ជាសាក្សីតែម្នាក់គត់ដែលបានឃើញព្រឹត្តិការណ៍ ដែលមានសារសំខាន់សម្រាប់អង្គជំនុំជម្រះដែលថា មានគោលនយោបាយកំណត់គោលដៅលើទាហាន និងមន្ត្រី សាធារណរដ្ឋ (សូមមើល **F16** បណ្ដឹងសាទុក្ខ កថាខណ្ឌ ៥៩៨)។ ការស៊ើបអង្កេតបន្ថែមដែលខ្លួនបានស្នើសុំទាក់ទងនឹងភស្តុតាងដែលគាត់បានផ្ដល់ជូន មានរួមទាំងសាក្សីដែលឃើញព្រឹត្តិការណ៍ ដែលជាលើកដំបូងដែលមេធាវីការពារក្ដីបានដឹងពីវត្តមាន។ សូមមើល "សំណើសុំឲ្យស៊ើបអង្កេតពីព្រឹត្តិការណ៍នៅក្នុងសក្ខីកម្ម សំ សិទ្ធី" ថ្ងៃទី ៧ ខែ កញ្ញា ២០១៥ (សំណើសំ សិទ្ធី) កថាខណ្ឌ ៣១។

[69] សូមមើល **F28** "សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរទៅលើព្រឹត្តិការណ៍នានាដែលពិពណ៌នានៅក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្ម សំ សិទ្ធី" ៧ សីហា ២០១៥ កថាខណ្ឌ ៣១។ ឯកសារ **F2/9** "សេចក្ដីសម្រេចលើសំណើសុំ" ទំព័រ៧។

[70] ឯកសារ **F2** សំណើលើកទីមួយសុំភ័ស្តុតាងបន្ថែម ទំព័រ ៥ (គូសបញ្ជាក់បន្ថែម)។

[71] ឯកសារ **F2** សំណើលើកទីមួយសុំភ័ស្តុតាងបន្ថែម ទំព័រ ៥ (គូសបញ្ជាក់បន្ថែម)។

នោះ នឹង "បញ្ជាក់អំពីការបង្ហាញអំពីជម្លោះដែលគេហៅថា*សង្គ្រាមស៊ីវិលសម្ងាត់នៅក្នុងរបបខ្មែរក្រហម ហៅថា ជម្លោះផ្នែកនយោបាយនៅក្នុងរបបខ្មែរក្រហម។ ហើយនឹងបង្ហាញអំពីអ្វីនៅពីខាងក្រោយការកាប់សម្លាប់នោះ*"[72]។ អាស្រ័យហេតុនេះ សំណើសុំភ័ស្តុតាងបន្ថែមលើកទីមួយរបស់មេធាវីការពារក្តី និងឯកសារមួយចំនួនដែលបានដាក់នាពេលក្រោយមកទៀត ផ្តោតលើការស្នើសុំភ័ស្តុតាងដែលមេធាវីការពារក្តីបានដឹងតាមរយៈកិច្ចសម្ភាសន៍របស់លោក សម្បត្តិ[73]។

28. ម្យ៉ាងវិញទៀត សំណើសុំមួយចំនួនផ្សេងទៀតរបស់មេធាវីការពារក្តីផ្តោតលើភ័ស្តុតាងដែលទើបតែរកបាននៅក្នុងដំណើរការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ ហើយទើបតែបានដាក់បង្ហាញជូនដល់មេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០២/០២ តែប៉ុណ្ណោះ[74]។ ភស្តុតាងនេះត្រូវបានបន្តប្រមូល បោះទោះជាបណ្តឹងសាទុក្ខកំពុងធ្វើឡើងក៏ដោយ និងខ្លះទៀតថែមទាំងនៅ*បន្ទាប់* ពីមេធាវីការពារក្តីបានដាក់សំណើលើកទីប្រាំ និងទីប្រាំមួយរបស់ខ្លួនដោយផ្តោតទៅលើការដាក់បង្ហាញនេះ[75]។ ដូចមេធាវីការពារក្តីបានពន្យល់នៅក្នុងសំណើសុំភ័ស្តុតាងបន្ថែមលើកទីប្រាំមួយ ករណីនេះគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ ហើយបានកើតឡើង មិនមែនដោយសារវិសាលភាពនៃសំណុំរឿង ០០២/០២ ផ្តល់លទ្ធភាពឲ្យពិនិត្យស្រាវជ្រាវមើលបញ្ហាធំធេងជាងក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែអ្វីដែលសំខាន់នោះ គឺដោយសារសំណុំរឿង ០០៣ និង ០០៤ ទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌនៅថ្នាក់ក្រោមៗ។ នេះជាទស្សនវិស័យយល់ឃើញមួយដែលមានចេតនាដកចេញពីក្នុងសំណុំរឿង ០០២/០១ ដោយសារការជ្រៀតជ្រែកផ្នែកនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាជិកជាន់ខ្ពស់បំផុតរបស់ខ្លួនធ្លាប់ជាអតីតសមាជិកដែលមានឋានន្តរសក្តិនៃ ប.ក.ក ដែលនឹងអាចត្រូវបានឆ្លើយដាក់ ប្រសិនបើទស្សនវិស័យនេះត្រូវបានពិនិត្យស្រាវជ្រាវមើល[76] ដោយសារវិសាលភាពនៅក្នុងសំណុំរឿង ០០២/០១ និងភាពកាន់តែ

---

[72] ឯកសារ **F2** សំណើលើកទីមួយសុំភ័ស្តុតាងបន្ថែម ទំព័រ ៧ (គូសបញ្ជាក់បន្ថែម)។

[73] ឯកសារ **F2** សំណើលើកទីមួយសុំភ័ស្តុតាងបន្ថែម។ ឯកសារ **F2/4/3/3/1** ចម្លើយតបលើឈុតវីដេអូរបស់ Lemkin និងសម្បត្តិ។ ឯកសារ **F2/4/3/3/6/1** ប្រតិចារឹក និងសារណាអំពី "ជម្លោះ"។

[74] ឯកសារ **F2/4** សំណើលើកទីបីសុំភ័ស្តុតាងបន្ថែម។ ឯកសារ **F2/7** សំណើលើកទីប្រាំសុំភ័ស្តុតាងបន្ថែម។ ឯកសារ **F2/8** សំណើលើកទីប្រាំមួយសុំភ័ស្តុតាងបន្ថែម។

[75] សូមមើលឯកសារដែលដាក់បង្ហាញដល់មេធាវីការពារក្តីដែលមេធាវីការពារក្តីទើបតែទទួលបាននៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ គឺតែប៉ុន្មានថ្ងៃនៅមុនពេលដាក់សំណើនេះ។ ឯកសារ **E319/40** ថ្ងៃទី២៩ មករា ២០១៦។

[76] *សូមមើល* ឯកសារ **F2/8** សំណើលើកទីប្រាំមួយសុំភ័ស្តុតាងបន្ថែម។

ខិតជិតគ្នារបស់អ្នកដឹកនាំថ្នាក់ក្រោម នៅក្នុងព្រឹត្តិការណ៍ដែលបានកើតឡើង។ ការគិតនេះ *នឹង* ត្រូវបានពិនិត្យប្រសិនបើមេធាវីការពារក្តីត្រូវបានអនុញ្ញាតឲ្យចូលរួមដោយប្រសិទ្ធិភាពនៅក្នុងការស៊ើបអង្កេត។ យើងអាចមានចម្ងល់ថា ការដាក់ភស្តុតាងថ្មី និងពាក់ព័ន្ធដែលត្រូវបានរកឃើញនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលជនសង្ស័យមានតួនាទីនៅក្នុង បកក ស្មើគ្នាទៅនឹងមេដឹកនាំក្នុងរដ្ឋាភិបាលបច្ចុប្បន្ន ហើយបានកាន់កាន់នៅតំបន់ផ្សេងគ្នា ហើយអាចឆ្លើយដាក់តិចតួចទៅដល់ថ្នាក់ដឹកនាំកំពូល។ បន្ថែមពីលើនេះទៀតនោះ ការបន្ថយការគ្រប់គ្រងការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ និង ០០៤ អាចទាក់ទងផងដែរទៅនឹងការពិតដែលថា ការស៊ើបអង្កេតនៅក្នុងសំណុំរឿងកំពុងត្រូវបានជម្រុញតែពីខាងអន្តរជាតិតែប៉ុណ្ណោះ ដោយសារតែរាជរដ្ឋាភិបាលកម្ពុជាជំទាស់នឹងសំណុំរឿងទាំងនេះ។

## III. ច្បាប់ជាធរមាន

## ច. សំណើសុំការពិចារណាឡើងវិញ

29. សំណើសុំការពិចារណាឡើងវិញពុំមានចែងក្នុងវិធានផ្ទៃក្នុងឡើយ។ ទោះយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាខ្លួននឹងពិនិត្យសំណើទាំងនេះ “នៅពេលពាក្យបណ្តឹងថ្មី មានភស្តុតាងថ្មី ឬមានកាលៈទេសៈថ្មីធ្វើជាយុត្តិកម្ម”[77]។ ដោយអនុវត្តតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTY អង្គបុរេជំនុំជម្រះបានកំណត់យកលក្ខខណ្ឌទូលំទូលាយជាងមុន ដោយបានសម្រេចថា សិទ្ធិអំណាចរបស់ខ្លួនក្នុងការពិចារណាសេចក្តីសម្រេចរបស់ខ្លួនឡើងវិញ អនុវត្តមិនត្រឹមតែក្នុងករណី “កាលៈទេសៈមានការផ្លាស់ប្តូរ” (ដែលអាចបណ្តាលមកពីមាន “អង្គហេតុ ឬទឡ្ហីករណ៍ថ្មី”[78]) ប៉ុន្តែគឺថែមទាំងក្នុងករណីដែលអង្គជំនុំជម្រះ “យល់ឃើញថាសេចក្តីសម្រេច

---

[77]ឯកសារ **E238/11/1**, “សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម”, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២ (“សេចក្តីសម្រេចលើសំណើសុំពិចារណាឡើងវិញអំពីសម្បទារបស់ អៀង សារី”), កថាខណ្ឌ ៧។

[78]សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២), ឯកសារ **D99/3/41**, “ សេចក្តីសម្រេចលើពាក្យសុំការពិចារណាឡើងវិញចំពោះសេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំនៅក្នុងសំណុំរឿង ឌុច”, ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៨, កថាខណ្ឌ៦។ សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Galic,* សំណុំរឿង IT-98-29, “សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពិចារណាឡើងវិញ”, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៤ (“សេចក្តីសម្រេច *Galic* លើការពិចារណាឡើងវិញ”), បុព្វកថាទី ៩។

លើកមុនមានកំហុស ឬ [...] បណ្តាលឲ្យមានភាពអយុត្តិធម៌”[79]។

30. អង្គជំនុំជម្រះសាលាដំបូងគ្មានហេតុផលដើម្បីឃ្លាតចាកពីលក្ខខណ្ឌទូលាយដែលប្រកាន់យកដោយអង្គបុរេជំនុំជម្រះ ដែលជាលក្ខខណ្ឌដែលត្រូវបានអនុវត្តជាទូទៅនៅតុលាការ ICTY។ មូលហេតុរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកំណត់លក្ខខណ្ឌរិតត្បិត គឺថា ភាគីមានសិទ្ធិប្តឹងសាទុក្ខជំទាស់សេចក្តីសម្រេចរបស់ខ្លួន[80]។ ទោះជាយ៉ាងនេះក៏ដោយ នៅតុលាការ ICTY ភាគីអនុវត្តទាំងសិទ្ធិប្តឹងសាទុក្ខ (រួមទាំងសិទ្ធិទូលំទូលាយដើម្បីដាក់បណ្តឹងសាទុក្ខបន្ទាន់បង្ខំ ដែលមិនមែនជាករណីនៅ អ.វ.ត.ក) និងសិទ្ធិស្នើទៅ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY សុំឲ្យពិចារណាសេចក្តីសម្រេចរបស់ខ្លួនឡើងវិញ ដោយសំអាងលើមូលដ្ឋាននានាដូចដែលបានបញ្ជាក់ខាងលើ។ អាស្រ័យហេតុនេះ មេធាវីការពារក្តី សូមអះអាងថាលក្ខខណ្ឌត្រឹមត្រូវសម្រាប់ការពិចារណាឡើងវិញនៅ អ.វ.ត.ក គ្របដណ្តប់មិនត្រឹមតែទៅលើ “ភ័ស្តុតាងថ្មី ឬកាលៈទេសៈថ្មី” ឡើយ ប៉ុន្តែគឺថែមទាំងគ្របដណ្តប់លើករណីនានា ដែលអង្គជំនុំជម្រះ “យល់ឃើញថា សេចក្តីសម្រេចលើកមុនមានកំហុស ឬ [...] បណ្តាលឲ្យមានភាពអយុត្តិធម៌”។

## ខ. សិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ

31. មាត្រា១៤(៥) នៃ*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ដែលត្រូវបានដាក់បញ្ចូលដោយផ្ទាល់ក្នុងច្បាប់កម្ពុជា[81] ដែលកម្ពុជាជារដ្ឋភាគី ចែងអំពីការធានានូវការជំនុំជម្រះប្រ

[79]ឯកសារ **D164/4/9**, “សេចក្តីសម្រេចលើសំណើសុំឲ្យពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេចទាក់ទងនឹងសំណើសុំឲ្យមានសវនាការដើម្បីពិនិត្យបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង អ.ប.ជ ២៤ និង ២៥”, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៩ (“សេចក្តីសម្រេចលើការពិនិត្យមើលឡើងវិញរបស់អង្គបុរេជំនុំជម្រះ”), កថាខណ្ឌ ១២។ ឯកសារ **C22/I/68**, សេចក្តីសម្រេចលើពាក្យសុំពិចារណាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង”, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨, កថាខណ្ឌ ២៥។ សេចក្តីសម្រេច *Galic* លើការពិចារណាឡើងវិញ, បុព្វកថាទី ៨។

[80] ឯកសារ **E238/11/1**, សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម,កថាខណ្ឌ ៧, កំណត់សម្គាល់ ២៤។

[81] រដ្ឋធម្មនុញ្ញកម្ពុជា,មាត្រា ៣១ ចែងថា “ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សិទ្ធិនារី និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ”។ *សូមមើលផងដែរ* ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា “សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ 092/003/2007 ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ ទាក់ទងលទ្ធភាពនៃការអនុវត្តសន្ធិសញ្ញាសិទ្ធិមនុស្ស

កបដោយយុត្តិធម៌ជាមូលដ្ឋានដែល "ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឲ្យសាលាក្ដីជាន់ខ្ពស់ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្ដន្ទាទោសឡើងវិញស្របតាមច្បាប់"។ គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប បានសម្រេចថាការផ្ដល់អានុភាពទៅសិទ្ធិនេះតម្រូវថា ពិរុទ្ធជន "អាច នៅក្នុងរយៈពេលសមស្រប ពិនិត្យសាលក្រមជាលាយលក្ខណ៍អក្សរ <u>ដែលមានសំអាងហេតុត្រឹមត្រូវ</u> ចំពោះបណ្ដឹងសាទុក្ខក្នុងគ្រប់ករណីទាំងអស់"[82]។ ហេតុដូច្នេះដូចដែលមាននៅក្នុងយុត្តិសាស្ត្រតុលាការសិទ្ធិមនុស្សអឺរ៉ុប[83] តុលាការ ICTY[84] និងតុលាការ ICTR[85] សិទ្ធិទទួលបានសេចក្ដីសម្រេចដែលមានសំអាងហេតុគឺជាធាតុផ្សំមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌[86]។ យោងតាមតុលាការសិទ្ធិមនុស្សអឺរ៉ុប និងតុលាការ ICTY "កម្រិតនៃការអនុវត្តសិទ្ធិនេះអាចខុសពីគ្នា អាស្រ័យទៅលើប្រភេទនៃសេចក្ដីសម្រេច [...និង] អាចត្រូវបានកំណត់ទៅតាមកាលៈទេសៈនៃករណី [នីមួយៗ]"[87]។ សិទ្ធិទទួលបានសម្អាងហេតុ គឺមាននៅក្នុងវិធាន ១០៨(៤) ដែលតម្រូវថា "សេចក្ដីសម្រេចដែលបានចេញ ក្នុងរយៈពេលកំណត់ខាងលើ ដោយអនុលោមតាមវិធាននេះ ត្រូវរួមបញ្ចូលនូវសេចក្ដីសង្ខេបនៃសំអាងហេតុ។ សំអាង

---

អន្តរជាតិដោយតុលាការកម្ពុជា" ដែលមាននៅលើគេហទំព័រ http://cambodia.ohchr.org/WebDOCs/DocPublications/CCBHR%20Constitution/CCBHR-EN.pdf (ទំព័រ ៣៧ *និងទំព័របន្ទាប់*)។

[82] *សំណុំរឿង Francis ទល់នឹង Jamaica,* UNHRC, Comm. លេខ 320/1988,ឯកសារ អ.ស.ប លេខ A/48/40 (វ៉ុល II), ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៣, កថាខណ្ឌ ១២.២ (សេចក្ដីបញ្ជាក់បន្ថែម)។

[83] *សូមមើល ឧទាហរណ៍* សំណុំរឿង *Hadjianastassiou ទល់នឹង Greece,* "សាលក្រម (Merits and Just Satisfaction), តុលាការសិទ្ធិមនុស្ស, ឯកសារលេខ 12945/87, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩២, កថាខណ្ឌ ៣៣។ *សំណុំរឿង Ruiz Torija ទល់នឹង Spain,* "សាលក្រម", តុលាការសិទ្ធិមនុស្សអឺរ៉ុប,ឯកសារលេខ 18390/91, ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៩៤,("សាលក្រម Hadjianastassiou"),កថាខណ្ឌ ២៩។

[84] *សូមមើលឧទាហរណ៍ សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Furundzija,* "សាលដីកាលើបណ្ដឹងសាទុក្ខ", លេខសំណុំរឿង IT-95-17/1-A, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ ("សាលដីកា Furundzija"), កថាខណ្ឌ ៦៩។

[85] *សូមមើល ឧទាហរណ៍ សំណុំរឿង Karera ទល់នឹង រដ្ឋអាជ្ញា,* "សាលក្រម", សំណុំរឿង ICTR-01-74-A, ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០០៩, កថាខណ្ឌ ២០។ *សំណុំរឿង Nchamihigo ទល់នឹង រដ្ឋអាជ្ញា,* សាលក្រម, សំណុំរឿងង ICTR-2001-63-A, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១០, កថាខណ្ឌ ១៦៥។

[86] *សូមមើល ឧទាហរណ៍* ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងកិច្ចសហការជាមួយគណៈមេធាវីអន្តរជាតិ, *Human Rigts in the Administration of Justice: A Manual on Human Rights for Judges, Prosecutors and Lawyers*, UN Doc. HR/P/PT/9, 2003, ទំព័រ ២៩៣។

[87] សាលក្រម Hadjianastassiou, កថាខណ្ឌ ២៩, សាលក្រម Furundzija, កថាខណ្ឌ ៦៩។

ហេតុពេញលេញនឹងត្រូវចេញឲ្យបានឆាប់តាមលទ្ធភាពដែលអាចធ្វើទៅបាន” ដែលតាមវិធាននេះ មេធាវីការពារក្តីលើកឡើងថា ត្រូវតែអនុវត្តចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលបានចេញនៅក្នុងបរិបទបណ្តឹងសាទុក្ខ។

## V. ឧឡារិករណ៍

32. ដោយមិនអាចដឹងអំពីមូលហេតុចម្បងនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើសំណើសុំដាក់ភស្តុតាងបន្ថែម មេធាវីការពារក្តីមិនអាចលើកឧឡារិករណ៍លម្អិតច្បាស់លាស់ដើម្បីស្នើសុំការពិចារណាឡើងវិញបានឡើយ។ ខណៈមេធាវីការពារក្តីពិចារណាថា គ្រប់សាក្សី និងភស្តុតាងដែលខ្លួនបានស្នើ គឺងាយស្រួលនឹងបំពេញលក្ខខណ្ឌក្នុងការទទួលយកសម្រាប់បណ្តឹងសាទុក្ខ ខ្លួននឹងរង់ចាំផងដែរនូវសម្អាងហេតុពេញលេញនៅមុនពេលពិចារណាទៅលើបណ្តឹងសាទុក្ខរបស់ខ្លួនទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើសំណើដែលមិនទាន់សម្រេច។

33. ទោះយ៉ាងណា នៅដំណាក់កាលនេះមេធាវីការពារក្តីសូមដាក់សំណើបន្ទាន់សុំការពិចារណាឡើងវិញអំពីចំណុចមួយចំនួននៃសេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម ពោលគឺសេចក្តីសម្រេចរបស់អង្គជំនុំជម្រះមិនកោះហៅសាក្សីសំខាន់បំផុតចំនួន ២ រូបរបស់មេធាវីការពារក្តីគឺ ហេង សំរិន និង Robert Lemkin និងមិនទទួលយកជាភស្តុតាងលើបណ្តឹងសាទុក្ខនូវកំណត់សម្គាល់ និងប្រតិចារឹករបស់លោក Lemkin។ បើទោះជាមិនទាន់មានសម្អាងហេតុរបស់អង្គជំនុំជម្រះក៏ដោយ ក៏មេធាវីដាក់សំណើបន្ទាន់នេះដោយសំអាងថា *គ្មានសំអាងហេតុដែលអង្គជំនុំជម្រះអាចផ្តល់* ដែលអាចក្រៅពីធ្វើសេចក្តីសន្និដ្ឋានថាសេចក្តីសម្រេចទាំងនោះមានកំហុស និងបណ្តាលឲ្យមានភាពអយុត្តិធម៌ធ្ងន់ធ្ងរចំពោះលោក នួន ជា។ សំណើសុំភស្តុតាងមិនគ្រាន់តែបំពេញលក្ខខណ្ឌតម្រូវសម្រាប់ទទួលយកសម្រាប់បណ្តឹងសាទុក្ខប៉ុណ្ណោះទេ ប៉ុន្តែវានឹងពិភាក្សាបន្តនៅខាងក្រោមដែលថា វាមិនអាចខ្វះបាន សំខាន់ ទាក់ទង និង អាចជឿជាក់បាន។

34. វិធីតែមួយគត់ដែលសេចក្តីសម្រេចលើសំណើអាចធ្វើទៅបាន ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា នួន ជា នឹងត្រូវបានដកការចោទប្រកាន់ទាំងស្រុងអំពីឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ និងត្រូវបានចោទប្រកាន់ទាក់ទងការសម្លាប់រង្គាលក្នុងអំឡុងពេល

ជម្លៀសប្រជាជនពីភ្នំពេញ[88]។ ដោយពិចារណាថា វាមិនអាចទៅរួចទេសម្រាប់មេធាវីការពារក្ដីរង់ចាំរហូតដល់សាលដីកាលើបណ្ដឹងសាទុក្ខត្រូវបានចេញ ដើម្បីពិនិត្យថា ការច្រានចោលការចោទប្រកាន់ដែលនឹងចេញមក។ ដូចនេះខ្លួនត្រូវតែធ្វើសំណើនេះឡើង។ ប្រសិនបើការលើកលែងការចោទប្រកាន់មិនមាន នោះសេចក្ដីសម្រេចមានសម្អាងហេតុពេញលេញក្នុងការមិនកោះហៅ ហេង សំរិន និង Robert Lemkin ឬក៏ការមិនទទួលយកកំណត់ត្រារបស់ Lemkin និងប្រតិចារិក ជាភស្តុតាងនឹងគ្រាន់តែជាផ្លាស់ប្ដូរកម្រិតភាពអយុត្តិធម៌ដែលប៉ះពាល់ដល់ នួន ជា។ តែកំហុសសំខាន់ៗនៅក្នុងសេចក្ដីសម្រេចនេះគឺនឹងនៅតែដដែល។

## ក. សំណើសុំការពិចារណាឡើងវិញអំពីសេចក្ដីសម្រេចមិនកោះហៅ ហេង សំរិន

35. ក្នុងសំណុំរឿង ០០២/០១ ហេង សំរិន (TCW-223)-ប្រធានសភាជាតិនាពេលបច្ចុប្បន្ន និងជាសមាជិកថ្នាក់កំពូលទីពីរនៃគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច[89]- នឹងពុំមែនត្រឹមតែជាអង្គហេតុសំខាន់បំផុត និងជាសាក្សីអត្តចរិតតែម្នាក់គត់របស់ នួន ជា នោះទេ ប៉ុន្តែថែមទាំងជាសាក្សីសំខាន់បំផុតតែម្នាក់គត់[90]។ មេធាវីការពារក្ដីបានពិភាក្សាយ៉ាងវែងអន្លាយរួចហើយអំពីសារៈសំខាន់របស់លោក ហេង សំរិន ក្នុងកិច្ចដំណើរការនីតិវិធីនានានៅតុលាការនេះ[91] និងបានចំណាយ ២ ទំព័រនៃមូលដ្ឋានបណ្ដឹងសាទុក្ខចំនួន ២២៣ និងទំព័រមួយចំនួននៃបណ្ដឹងសាទុក្ខរបស់ខ្លួនដើម្បីបញ្ជាក់អំពីបញ្ហានេះ និងស្នើសុំឱ្យគាត់បង្ហាញខ្លួនជាសាក្សីលើបណ្ដឹងសាទុក្ខ[92]។ ទោះយ៉ាងណា បញ្ហានេះទាមទារឱ្យមានការលើកឡើងជាថ្មីម្ដងហើយម្ដងទៀត។

---

[88] ឯកសារ F16, បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៧៥។

[89] សូមមើល គណបក្សប្រជាជនកម្ពុជា "សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍" នៅលើគេហទំព័រ http://www.cpp.org.kh/%E1%9E%9F%E1%9E%98%E1%9E%B6%E1%9E%87%E1%9E%B7%E1%9E%80%E1%9E%82%E1%9E%8E%E1%9E%94%E1%9E%80%E1%9F%92%E1%9E%9F%E1%9E%94%E1%9F%92%E1%9E%9A%E1%9E%87%E1%9E%B6%E1%9E%87%E1%9E%93%E1%9E%80%E1%9E%98%E1%9F%92/ ។

[90] *សូមមើល ឧទាហរណ៍* ឯកសារ **E236/5/1/1**, "សំណើលើកទីប្រាំមួយ និងចុងក្រោយសុំកោះហៅសាក្សី TCW-223", ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣ ("សំណើ ហេង សំរិន លើកទីប្រាំមួយ") ឯកសារ **E295/6/3**, "សារណារបស់ នួន ជា បញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ("សារណាបញ្ចប់ការពិភាក្សាដេញដោល") ។

[91] សម្រាប់សេចក្ដីសង្ខេប *សូមមើល* ឯកសារ **E236/5/1/1**, សំណើ ហេង សំរិន លើកទីប្រាំមួយ និង **E314/6** បណ្ដឹងជិតចិត្តអង្គជំនុំជម្រះសាលាដំបូងលើកទីពីរ, កថាខណ្ឌ ៣៨-៤០។

[92] *សូមមើល* ជាទូទៅ ឯកសារ **F16**, បណ្ដឹងសាទុក្ខ, កថាខណ្ឌ ៥៨-៧៥។

### *(i) សារសំខាន់ និងមានតែមួយគត់ចេញពីសក្ខីកម្ម ហេង សំរិន*

36. ហេង សំរិន អាចផ្តល់ភ័ស្តុតាងផ្ទាល់ និងភស្តុតាងដោះបន្ទុកពិសេសខុសពីគេ ក្នុងនាមជាមន្ត្រីយោធា ប.ក.ក ជាន់ខ្ពស់បំផុត ដែលនៅរស់ ដែលបានចូលរួម និងទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះការជម្លៀសប្រជាជនពីភ្នំពេញ។ ដូចដែលមេធាវីការពារក្តីបានលើកទឡ្ហីករណ៍នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន ហេង សំរិន ទទួលខុសត្រូវជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដូច ឌុច ទទួលខុសត្រូវមន្ទីរ ស-២១៖ បុគ្គលម្នាក់ដែលត្រូវបានចាត់តាំងឲ្យដឹក នាំការអនុវត្តគោលនយោបាយនានាដែលសហព្រះរាជអាជ្ញា លើកឡើងថាត្រូវបានអនុម័តដោយ ប.ក.ក នៅទីតាំងឧក្រិដ្ឋកម្មមួយក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មសំខាន់បំផុតទាំងឡាយ ដូចមានចោទក្នុងដីកាដំណោះស្រាយ[93]។ ជាមនុស្សស្ថិតក្រោម សោ ភឹម តែ ២ ថ្នាក់ នៅក្នុងឋានានុក្រមភូមិភាគបូព៌ានៅឆ្នាំ ១៩៧៥ ហេង សំរិន ក៏ប្រាកដជាមានការដឹងឮដោយផ្ទាល់អំពីបទបញ្ជានានាដែលចេញពីថ្នាក់កំពូលនៃយោធាភូមិភាគនេះ[94]។ លើសពីនេះ កិច្ចសម្ភាសន៍ជាមួយ ហេង សំរិន ដែលធ្វើឡើងដោយ Ben Kiernan គឺជាភ័ស្តុតាងផ្ទាល់តែមួយគត់នៅក្នុងសំណុំរឿងនៃចេតនារបស់ នួន ជា ចំពោះទាហាន និងអ្នករដ្ឋការសាធារណរដ្ឋខ្មែរ[95]។ ហេង សំរិន អាចលើកកម្ពស់យ៉ាងខ្លាំងដល់ការយល់ដឹងរបស់តុលាការអំពីគោលនយោបាយ និងមូលដ្ឋាននៃបទល្មើស ក្រោមការពិភាក្សាក្នុងសំណុំរឿង ០០២/០១, ក្នុងនោះរួមទាំងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គោលនយោបាយសម្លាប់វង្គាល និងការធ្វើទុក្ខបុកម្នេញរបស់ ប.ក.ក ដែលត្រូវបានចោទប្រកាន់ ពាក់ព័ន្ធជាមួយការជម្លៀសនោះ និងគោលនយោបាយ ប.ក.ក សំខាន់បំផុតដែលត្រូវបានចោទប្រកាន់ក្នុងការសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរជាទូទៅ និងជាពិសេសនៅទួលពោធិ៍ជ្រៃ។

---

[93] ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៦២។

[94] ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៥៩។ ឯកសារ **E236/5/1/1**, សំណើ ហេង សំរិន លើកទីប្រាំមួយ, កថាខណ្ឌ ៥។ *សូមមើលផងដែរ* ឯកសារ **E370**, "សំណើបន្ទាន់ និងរួមគ្នារបស់ នួន ជា សុំឲ្យពន្លឿនសំណើពីររបស់ខ្លួនដែលបានស្នើរួចហើយ និងសុំឲ្យកោះហៅសាក្សីបន្ថែមបួនរូបពាក់ព័ន្ធការប្រព្រឹត្តិចំពោះជនជាតិចាម ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ("សំណើសាក្សីចាមភូមិភាគបូព៌ា"), កថាខណ្ឌ ២០។

[95] ឯកសារ **E3/1568**, "វាយឡើងវិញពីកិច្ចសម្ភាសន៍ដែលសរសេរដៃជាមួយ ជា ស៊ីម, ភ្នំពេញ ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ១៩៩១, និង ហេង សំរិន, ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៩១" ERN 00651884, **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៥៩, ឯកសារ **E295/6/3**, សារណាបញ្ចប់ការពិភាក្សាដេញដោល, កថាខណ្ឌ ៣៦។

37. បន្ថែមពីលើចំណុចខាងលើ ហេង សំរិន អាចផ្តល់ការយល់ដឹងស៊ីជម្រៅអំពីបញ្ហានានាដែលជាចំណុចសំខាន់នៃសំណុំរឿងរបស់មេធាវីការពារក្តី ដែលត្រូវបានដកចេញពីក្នុងសំណុំរឿង០០២/០១ អំពីអ្វីដែលអង្គជំនុំជម្រះតុលាការកំពូលហៅថា "ជម្លោះផ្ទៃក្នុង" តែ ហេង សំរិន ហៅថា "ការតស៊ូសម្ងាត់"[96]។ ជាពិសេស និងដូចដែលមេធាវីការពារក្តីបានលើកពីពេលមុនរួចមកហើយ ហេង សំរិន ជាប់ពាក់ព័ន្ធដោយផ្ទាល់ក្នុងទំនាស់ភូមិភាគក្នុងចំណោមកម្លាំងដែលរំដោះភ្នំពេញហើយ អាស្រ័យហេតុនេះគាត់អាចផ្តល់សក្ខីកម្មថ្មីពីមន្រ្តីជាន់ខ្ពស់លើបញ្ហានេះ[97]។ លើសពីនេះ ក្នុងនាមជាប្រធានរណសិរ្សសាមគ្គីសង្គ្រោះជាតិ ដែលបានសហការជាមួយ វៀតណាម ដើម្បីចូលលុកលុយកម្ពុជាក្នុងខែ ធ្នូ ឆ្នាំ ១៩៧៨[98] និងជាមេដឹកនាំនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (រដ្ឋអាយ៉ងវៀតណាម ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ)[99] ច្បាស់ណាស់ថា ហេង សំរិន អាចផ្តល់សក្ខីកម្មដែលគ្មាន អ្នកជំនួសបានដែលនឹងចូលទៅក្នុងចំណុចស្នូលនៃសំណុំរឿងរបស់មេធាវីការពារក្តី។ គាត់អាចរៀបរាប់ផងដែរពីរបៀបដែលមេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក បានព្យាយាមបង្ការការបះបោរ និង/ឬ អំពើក្បត់ ប.ក.ក និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនៅភ្លាមៗបន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[100] ដោយមានការគាំទ្រពីវៀតណាម និងមានសូវៀតជាខ្នងបង្អែក[101]។

38. ភស្តុតាងរបស់ ហេង សំរិន នឹងតតាំងដោយផ្ទាល់ជាមួយការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលផ្លាស់ប្តូរការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ នួន ជា ដែលថា រចនាសម្ព័ន្ធ ប.ក.ក មាន "ឋានានុក្រម តឹងតែង" "ជាសណ្ឋានពីរ៉ាមីត" និងត្រូវបានធ្វើឯកភាពរូបនីយកម្ម និងដែលថាបញ្ជានោះគឺមកពីថ្នាក់លើត្រូវបានគោរពយ៉ាងតឹងរ៉ឹងដោយមិនមានការប្រែប្រួល។

39. សំខាន់ជាងគេ ហេង សំរិន ក៏អាចផ្តល់ភស្តុតាងអត្តចរិតតែមួយគត់ ក្នុងនាមជាសាក្សីអត្តចរិតតែម្នាក់គត់របស់ នួន ជា។ បុរសទាំង ២ នាក់នេះ បានស្គាល់គ្នាចំនួន ៦០ ឆ្នាំ និងបានធ្វើការងារជាមួយគ្នាចំនួន ២ ទសវត្សរ៍ ដោយ ហេង សំរិន ថែមទាំងបានធ្លាប់ធ្វើជានិរសាររបស់ នួន ជា មួយ

---

[96] សូមមើល **E3/1568** Kiernan សម្ភាស ជា ស៊ីម-ហេង សំរិន ERN 00651889។

[97] ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៦៤។

[98] ឯកសារ **F2/8**, សំណើភស្តុតាងបន្ថែមលើកទីប្រាំមួយ, កថាខណ្ឌ ៦១។

[99] ឯកសារ **F2/8**, សំណើភស្តុតាងបន្ថែមលើកទីប្រាំមួយ, កថាខណ្ឌ ៦៥។

[100] ឯកសារ **F2/8**, សំណើភស្តុតាងបន្ថែមលើកទីប្រាំមួយ, កថាខណ្ឌ ៣១ដល់៣៣។

[101] *សូមមើល ឧទាហរណ៍* ឯកសារ **F2/8**, សំណើភស្តុតាងបន្ថែមលើកទីប្រាំមួយ, កថាខណ្ឌ ១០-១២។

រយៈទៀតផង។ ស្ទើរតែគ្មាននរណាម្នាក់ដែលនៅរស់ក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ដែលមានទំនាក់ទំនងមិត្តភាពយូរអង្វែង និងជិតស្និទ្ធជាមួយ នួន ជា ក្នុងអំឡុងបដិវត្តន៍សង្គមនិយម និងគ្មាននរណាម្នាក់បានចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការនេះឡើយ[102]។

### *(ii)* *កំហុស និង ផលប៉ះពាល់នៃស្ថាប័នលម្អៀង*

40. ជាសង្ខេប សក្ខីកម្មសក្តានុពលរបស់ ហេង សំរិន ក្នុងសំណុំរឿង ០០២/០១ មានតម្លៃខ្ពស់ខុសស្រឡះពីសក្ខីកម្មរបស់រាល់សាក្សីដទៃទៀតក្នុងសំណុំរឿង ០០២/០១។ ផ្ទុយទៅវិញ ជំនួសឱ្យការទទួលបានសក្ខីកម្មរបស់គាត់ សាលក្រមបានសំអាងលើសក្ខីកម្មរបស់ទាហានថ្នាក់ក្រោមបំផុត[103] និង "អ្នកជំនាញ" បរទេស សម្រាប់បញ្ហាទាំងអស់នេះ នៅពេលដែលចៅក្រមជាតិបានសន្និដ្ឋានថា ជាការគ្រប់គ្រាន់ដើម្បីសំអាងលើការសម្ភាសន៍របស់អ្នកស្រាវជ្រាវជាមួយ ហេង សំរិន ដែលត្រូវបានបោះពុម្ពផ្សាយ ដោយមិនផ្តល់ឱកាសទៅភាគី ដើម្បីសួរដេញដោលគាត់[104]។ ផលវិបាកនៃស្ថានភាពបែបនេះស័ក្តិសមការពិពណ៌នារបស់ចៅក្រម Christine Van den Wyngaert នៅក្នុងទស្សនៈរបស់ចៅក្រមមតិភាគតិច ក្នុងសំណុំរឿង *Katanga* នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ៖

> អវត្តមានទាំងស្រុងនៃភស្តុតាងពីបុគ្គលទាំងឡាយដែលស្ថិតនៅចំណុចកណ្តាលនៃរឿងរ៉ាវ កាលពីពេលនោះបង្កើតដោយជៀសមិនផុតនូវការយល់ឃើញថា ព័ត៌មានសំខាន់ កំពុងបាត់បង់ពីកំណត់ហេតុ [...និងអាចនាំឱ្យគេ] ឆ្ងល់ថាតើវាអាចបំពេញលក្ខខណ្ឌតម្រូវដែរ ឬយ៉ាងណា [...] នៅពេលដែលមានភាពជាក់ច្បាស់ថា ភស្តុតាងកាន់តែច្រើន និងកាន់តែប្រសើរ អាចនាំឱ្យមាន ចម្លើយផ្សេងពីនេះដ៏គួរឱ្យកត់សម្គាល់[105]។

---

[102] *សូមមើល,* ឯកសារ **E236/5/1/1**, សំណើ ហេង សំរិន លើកទីប្រាំមួយ, កថាខណ្ឌ ៦,១៣។ ឯកសារ **E236/5/1**, "សំណើសុំកោះហៅសាក្សី TCW-223 ដែលពាក់ព័ន្ធនឹងអត្តចរិតរបស់ នួន ជា, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[103] ឧទាហរណ៍ចំនួន ២ គឺសាក្សី ស៊ុំ ជា ដែលមានឋានៈយោធាទាបបំផុត (ជាកូនទាហានធម្មតា) និងសាក្សី គង់ គីម ដែលមានតួនាទីបន្ទាប់ពីថ្នាក់ក្រោមបំផុតជាមេក្រុម។

[104] ឯកសារ **E312**, "សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចស្តាពរស្តីពីសាក្សី"), កថាខណ្ឌ ៩៨, ១០២។

[105] សំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Katanga,* សំណុំរឿង ICC-01/04-01/07, "មតិភាគតិចរបស់ចៅក្រម Christine Van den Wyngaert", ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៤ ("មតិរបស់ Van den Wyngaert Katanga"), កថាខណ្ឌ ១៤៨-១៤៩ (សេចក្តីបញ្ជាក់បន្ថែម)។

41. ដោយសារ ហេង សំរិន ជាសាក្សីសំខាន់តែម្នាក់គត់ ទើបមេធាវីការពារក្តីបានស្នើសុំជារឿយៗឱ្យកោះហៅគាត់ ឬស៊ើបអង្កេតអំពីបញ្ហាពាក់ព័ន្ធនានានៅដំណាក់កាលមុនការជំនុំជម្រះ[106] (ប្រាំមួយលើក) នៅដំណាក់កាលសវនាការ[107] និងនៅដំណាក់កាលបណ្តឹងសាទុក្ខនាពេលបច្ចុប្បន្ន[108]។ ទោះបីជាចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះតុលាការកំពូលពុំទាន់ប្រកាន់ជំហរជាក់លាក់ចំពោះ ហេង សំរិន ក៏ដោយ ក៏ចៅក្រមអន្តរជាតិម្នាក់ៗ និងចៅក្រមគ្រប់រូបដែលបានទទួលសំណើទាំងនេះនៅដំណាក់កាលស៊ើបសួរ ដំណាក់កាលមុនការជំនុំជម្រះ និងដំណាក់កាលសវនាការសុទ្ធតែយល់ថា សំណើទាំងនេះទាមទារឱ្យមានចំណាត់ការ[109] ហើយសហព្រះរាជអាជ្ញាអន្តរជាតិទាំងពីរក៏យល់ដូច្នេះដែរ[110]។ ក្នុងឆ្នាំ ២00៩ ចៅក្រម Lemonde បានកោះហៅ ហេង សំរិន ដើម្បីស្តាប់ចម្លើយ ដោយបានជម្រាបគាត់ថាការស្តាប់ចម្លើយរបស់គាត់នឹង "នាំទៅដល់ការបញ្ជាក់អំពីការ

---

[106] *សូមមើល ឧទាហរណ៍* ឯកសារ **E314/2/7**, "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី", ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១០, *លើកក្នុង*ឯកសារ **E312**, សេចក្តីសម្រេចស្តាពរស្តីពសាក្សី ជើងទំព័រ ១៥៨។

[107]សម្រាប់សេចក្តីសង្ខេបនៃប្រវត្តិនីតិវិធីនៃសំណើទាំងនេះ, *សូមមើល* ឯកសារ **E236/5/1/1**, សំណើ ហេង សំរិន លើកទីប្រាំមួយ, កថាខណ្ឌ ៣-៨។

[108] ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៧៣០(ក)។

[109] ទាក់ទង ស.ច.ស Lemonde, *សូមមើល ឧទាហរណ៍* ឯកសារ E312, សេចក្តីសម្រេចលើសាក្សីស្តាពរ, កថាខណ្ឌ ៩០, និងឯកសារ **189/3/1/7.1.3**, "Un Juge Face aux Khmers Rouges", ទំព័រ ១៧២ (ដែលក្នុងនោះ ចៅក្រម Lemonde បានចាត់ទុក ហេង សំរិន ជា "qu'il nous fallait absolument interroger", ដែលត្រូវបានលើកឡើងក្នុងឯកសារ **E236/5/1/1**, សំណើ ហេង សំរិន លើកទីប្រាំមួយ,ជើងទំព័រ ១០)។ ទាក់ទងចៅក្រមនៃ អ.ប.ជ Downing និង Marchi-Uhel, *សូមមើល ឧទាហរណ៍* ឯកសារ **D314/1/12**, សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី, ("សាលដីកាលើកទីពីររបស់ អ.ប.ជ លើសាក្សី"), ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០ (ទោះជាសំណៅសាធារណៈដែលមានការកោសលុបនៃសេចក្តីសម្រេចនេះពុំបង្ហាញអត្តសញ្ញាណរបស់សាក្សីឡើយ ក៏សេចក្តីសម្រេចសាក្សីស្តាពរ បានបង្ហាញអំពីអត្តសញ្ញាណសាក្សី, *សូមមើល* ឯកសារ **E312**, សេចក្តីសម្រេចសាក្សីស្តាពរ, កថាខណ្ឌ ៩១ និងជើងទំព័រ ១៥៨)។ ទាក់ទងចៅក្រមនៃ អ.ជ.ស.ជ Cartwright និង Lavergne, *សូមមើល* ឯកសារ **E312**, សេចក្តីសម្រេចសាក្សីស្តាពរ, កថាខណ្ឌ ១០៤-១១១ និង ១១៩-១២០។

[110] ទាក់ទងនឹងព្រះរាជអាជ្ញារងអន្តរជាតិ **Cayley** សូមមើល **D314/1/5** "សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះបណ្តឹងឧទ្ធរណ៍របស់ អៀង សារី និង នួន ជា ស្តីពីការកោះហៅសាក្សីបន្ថែម" ២៩ មិនា ២០១០។ ទាក់ទងនឹងសហព្រះរាជអាជ្ញាអន្តរជាតិ Koumjian សូមមើល **E1/240.1** ប្រតិចារិក ថ្ងៃទី ៣០ កក្កដា ២០១៤ ទំព័រ១១២ បន្ទាត់ ១៤ដល់២២។

ពិត"[111]។ ក្នុងឆ្នាំ ២០១០ ចៅក្រម Downing និង Marchi-Uhel បានបង្ហាញទស្សនៈថា "ការរាំងសត្តីកម្មពីសាក្សីនានាដែលត្រូវបានចាត់ទុកថាអាចនាំទៅដល់ការបញ្ជាក់អំពីការពិត អាចរំលោភភាពត្រឹមត្រូវនៃការជំនុំជម្រះ"[112]។ ក្នុងសភាពចម្រូងចម្រាសបំផុត ចៅក្រម Cartwright និងចៅក្រម Lavergne បានបញ្ជាក់ក្នុងមតិជំទាស់របស់ពួកគាត់ ដែលត្រូវបានកប់ក្នុងសេចក្តីសម្រេចសាក្សីស្ថាពរក្នុងសំណុំរឿង ០០២/០១ ("សេចក្តីសម្រេចសាក្សីស្ថាពរ") ជាជាងត្រូវបានលើកឡើងក្នុងសាលក្រមថាសត្តីកម្មសក្តានុពលរបស់ ហេង សំរិន គឺ "មានភាពពាក់ព័ន្ធ*តាមការវិភាគបឋម* និងអាចជួយដល់អង្គជំនុំជម្រះក្នុងការបញ្ជាក់អំពីការពិត" និងអាចមាន "ព័ត៌មានដែលសាក្សីដទៃទៀត [មិន] ដឹងក្នុងសំណុំរឿង ០០២/០១"[113]។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគាត់បានបដិសេធព្រមៗគ្នាមិនព្រមសម្រេចលើអំណះអំណាងរបស់មេធាវីការពារក្តីដែលថា ការខកខានពុំបានកោះហៅ ហេង សំរិន ជាការរំលោភសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[114] ដូចដែលនឹងពិភាក្សាបន្ថែមខាងក្រោមនេះ[115]។

42. ផ្ទុយទៅនឹងការយល់ឃើញរបស់ចៅក្រមនិងសហព្រះរាជអាជ្ញាអន្តរជាតិ ព្រមទាំងម្នាក់ៗ និងគ្រប់ចៅក្រមជាតិដែលបានទទួលសំណើរបស់មេធាវីការពារក្តីសុំឱ្យកោះហៅ ហេង សំរិន ជារឿយៗ បានច្រានចោលសំណើទាំងនោះ ពោលគឺទាំងចៅក្រមស៊ើបអង្កេត ចៅក្រមនៃ អ.ប.ជ និងចៅក្រមសាលាដំបូង[116]។ សហព្រះរាជអាជ្ញាជាតិ ជា លាង បានរក្សាការជំទាស់របស់ខ្លួនតាំងពីដើមមកក្នុងការកោះហៅ ហេង សំរិន[117]។ នេះបញ្ជាក់អះអាងអំពីអត្ថិភាពនៃការបាក់បែកទាំងស្រុងជាបន្ត

---

[111] ឯកសារ **E136/3/1**, "លិខិតផ្ញើជូនសម្តេច ហេង សំរិន", ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩, ទំព័រ ១។

[112] ឯកសារ **E314/1/12**, សាលដីកាលើកទីពីររបស់ អ.ប.ជ លើសាក្សី , កថាខណ្ឌ ១២ (នៃមតិភាគតិច)។

[113] ឯកសារ **E312**,សេចក្តីសម្រេចសាក្សីស្ថាពរ, កថាខណ្ឌ ១០៨។

[114] ឯកសារ **E312**,សេចក្តីសម្រេចសាក្សីស្ថាពរ, កថាខណ្ឌ ៧០។ ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៧០។ ឯកសារ **E295/6/3**,សារណាបញ្ចប់ការពិភាក្សាដេញដោល, កថាខណ្ឌ ៣៨-៤៣។

[115] *សូមមើល ខាងក្រោម,* កថាខណ្ឌ ៣៥-៣៦។

[116] ពាក់ព័ន្ធចៅក្រមស៊ើបអង្កេត ប៊ុនឡេង, *សូមមើល ឧទាហរណ៍* **D314/1/12**, សាលដីកា អ.ប.ជ ទីពីរលើសាក្សី, កថាខណ្ឌ ៩ និងឯកសារ **E312**, សេចក្តីសម្រេចសាក្សីស្ថាពរ, កថាខណ្ឌ ៩០-៩១។ ពាក់ព័ន្ធចៅក្រមអង្គបុរេជំនុំជម្រះ គឹមសាន, ជុល និង វុទ្ធី, *សូមមើល ឧទាហរណ៍* ឯកសារ **D314/1/12**, សាលដីកា អ.ប.ជ ទីពីរលើសាក្សី។ ទាក់ទងចៅក្រមសាលាដំបូង ណុន, សុខន និង ឧត្តរា,*សូមមើល* **E312**, សេចក្តីសម្រេចសាក្សីស្ថាពរ, កថាខណ្ឌ ៨៧-៩៨, ១០១-១០៣, និង ១១៦-១២០។

[117] សូមមើល **E9/14/1/1/1** "ការជំទាស់បន្ថែម និងការកត់សម្គាល់របស់សហព្រះរាជអាជ្ញាទៅនឹងសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយភាគីដទៃ" ១១ មីនា ២០១១ និង **E9/14/1/1/1.1** "ឧបសម្ព័ន្ធបន្ថែមនៃការជំទាស់របស់សហព្រះរាជអាជ្ញា

បន្ទាប់រវាងចៅក្រម សហព្រះរាជអាជ្ញាជាតិ និងចៅក្រម សហព្រះរាជអាជ្ញាអន្តរជាតិអំពីបញ្ហានេះ។ ជាការពិត ប្រសិនបើសំអាងហេតុពេញលេញចំពោះសេចក្តីសម្រេចលើសំណើសុំដាក់ភ័ស្តុតាង បង្ហាញអំពីការបាក់បែកដូចគ្នានេះរវាងសមាជិកជាតិ និងសមាជិកអន្តរជាតិនៃអង្គជំនុំជម្រះតុលាការកំពូល ពេលនោះបញ្ហានៃការកោះហៅ ហេង សំរិន នឹងមិនគ្រាន់តែបញ្ជាក់អំពីការបែកបាក់យ៉ាងធ្ងន់ធ្ងររវាងភាគីជាតិ និងភាគីអន្តរជាតិទាំងមូលនៃតុលាការអ.វ.ត.ក ប៉ុណ្ណោះឡើយ គឺថែមទាំងអាចក្លាយជាគំរូតំណាងឲ្យផលប៉ះពាល់នៃវិការៈធ្ងន់ធ្ងរ(ដែលអាចប្រមើលឃើញ) ដែលចាក់ឫសនៅក្នុងស្ថាប័ន អ.វ.ត.ក។ ប្រការនេះនឹងធ្វើឲ្យគេជឿអ្នកទាំងឡាយ ដែលបានលើកឡើងថាតុលាការប្រាកដជាជៀសមិនផុតពីបរាជ័យតាំងពីដំបូង។ ប្រេងសាំងនឹងប្រាកដជាត្រូវបានបន្ថែមទៅលើភ្លើង ប្រសិនបើដូចគ្នានេះ អង្គជំនុំជម្រះសាលាដំបូងនឹងទំនងជាបដិសេធមិនកោះហៅ ហេង សំរិន ក្នុងសវនាការដែលកំពុងប្រព្រឹត្តទៅលើសំណុំរឿង ០០២/០២ ដែលហាក់បង្ហាញថា វាកាន់តែទំនងជាអាចកើតឡើង[118]។

43. លើសពីនេះ ការខកខានពុំបានកោះហៅ ហេង សំរិន ឲ្យមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ រួមទាំងពីសំណាក់អង្គជំនុំជម្រះតុលាការកំពូលនាពេលបច្ចុប្បន្ន ពិតជាពុំមែនគ្រាន់តែជាសំណួររបស់អ្នកស្រាវជ្រាវប៉ុណ្ណោះ។ ដូចដែលមេធាវីការពារក្តីបានលើកទឡ្ហីករណ៍លើបណ្តឹងសាទុក្ខ ការបែកបាក់នេះស្មើនឹងការរំលោភដ៏កម្រោលទៅលើសិទ្ធិរបស់ នួន ជា ដើម្បីទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ដោយតុលាការឯករាជ្យ[119]។ វាថែមទាំងរំលោភសិទ្ធិរបស់គាត់ដើម្បីធ្វើការការពារក្តី តាមរយៈការមិនដាក់បញ្ចូលភ័ស្តុតាងដោះបន្ទុកដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបទចោទប្រកាន់ទាំងឡាយដែលស្ថិតក្រោមការពិភាក្សាក្នុងសំណុំរឿង០០២/០១ និងការទទួលខុសត្រូវ

---

ជាតិទៅនឹងការស្នើសុំឲ្យកោះហៅសាក្សីរបស់ភាគីដទៃ" ៣០ ឧសភា២០១៤។ ប្រតិចារិក ថ្ងៃ ៣០ កក្កដា ឆ្នាំ២០១៤ ទំព័រ ១១៣ បន្ទាត់ ៥។

[118] *សូមមើល* ឯកសារ **E370**, សំណើសាក្សីចាមភូមិភាគបូព៌ា។ ឯកសារ **E370/3**, "សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឲ្យពន្លឿនការកោះហៅសាក្សីពីររូបដែលបានស្នើសុំរួចហើយ និងសុំឲ្យកោះហៅសាក្សីបន្ថែមនៅក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះក្រុមគោលដៅជាក់លាក់ ជនជាតិចាម (សំអាងហេតុពេញលេញនឹងចេញពេលក្រោយ)", ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥។

[119] សម្រាប់ភ័ស្តុតាងដែលថាតុលាការកម្ពុជាពុំមានឯករាជ្យផ្នែករចនាសម្ព័ន្ធពីរាជរដ្ឋាភិបាលកម្ពុជា និងថាចៅក្រមជាតិនៅតុលាការនេះពុំអាចអនុវត្តផ្ទុយពីការណែនាំ និងបំណងរបស់រដ្ឋាភិបាល, *សូមមើល,* ឯកសារ **E314/6**។ បណ្តឹងជិតចិត្តអង្គជំនុំជម្រះសាលាដំបូងលើកទីពីរ, កថាខណ្ឌ ៤៣-៤៩។ *សូមមើល ផងដែរ* ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៥៤-៧៥។

កាន់តែទូលំទូលាយរបស់ នួន ជា ចំពោះហេតុការណ៍នានាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[120]។

44. នៅក្នុងសេចក្តីសម្រេចចុងក្រោយរបស់ខ្លួនលើសាក្សី ចៅក្រម Cartwright និង Lavergne បានសម្រេច ទាក់ទងនឹងអំណះអំណាងរបស់ នួនជា ដែលថា សិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ត្រូវបានរំលោភ ដោយអង្គជំនុំជម្រះសាលាដំបូងដោយខកខានមិនបានកោះហៅ ហេង សំរិន និង អ៊ុក ប៊ុនឈឿន៖

> យើងយល់យ៉ាងច្បាស់ថា ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ បញ្ហានេះអាចនឹងត្រូវបានដោះស្រាយដោយសារតែអង្គជំនុំជម្រះតុលាការកំពូល មានអំណាចកោះហៅសាក្សី និងទទួលខុសត្រូវក្នុងការកំណត់ចុងក្រោយ អំពីផលប៉ះពាល់ណាមួយដែលកើតចេញពីការខកខានមិនបានកោះហៅសាក្សី។ ដែលពិចារណាទៅលើលទ្ធផលនេះ យើងមិនបញ្ចេញមតិយោបល់អំពីបញ្ហានៃភាពអយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីក្នុងការជំនុំជម្រះ ដែលសហសេវិកជាតិរបស់យើងលើកលើងនោះទេ[121]។

មេធាវីការពារក្តីបានលើកទឡ្ហីករណ៍ក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនថា ការបដិសេធដ៏កំសាក[122] របស់ចៅក្រម Cartwright និងចៅក្រម Lavergne ពុំសម្រេចអំពីបញ្ហានៃការរំលោភសិទ្ធិរបស់ នួន ជា ដើម្បីទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ គឺជា "ការផ្ទេរការទទួលខុសត្រូវចុងក្រោយបន្ទាប់ពីការអនុវត្តការផ្ទេរការទទួលខុសត្រូវយ៉ាងស្ពាត់ជំនាញរយៈពេលជាច្រើនឆ្នាំ"[123]។ នៅពេលនេះ ការទទួលខុសត្រូវធ្លាក់ទៅលើអង្គជំនុំជម្រះតុលាការកំពូល។ នៅក្នុងសំណើបន្ទាន់នេះ ចៅក្រមមានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពចំនួនតែ២ប៉ុណ្ណោះ៖ ទីមួយ គឺកោះហៅ ហេង សំរិន ឱ្យមកផ្តល់សក្ខីកម្មលើបណ្តឹងសាទុក្ខ ឬទីពីរគឺដកការចោទប្រកាន់ នួន ជា អំពីបទសម្លាប់រង្គាលចំពោះការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ព្រមទាំងបទចោទប្រកាន់ទាំងអស់ពាក់ព័ន្ធការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃ[124]។ ឧបមាថា

---

[120] ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៥៤-៧៥។

[121] ឯកសារ **E312** "សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១" កថាខណ្ឌ ១១១។

[122] *សូមមើលផងដែរ* ឯកសារ **E314/6**, បណ្តឹងជិតចិត្តអង្គជំនុំជម្រះសាលាដំបូងលើកទីពីរ, កថាខណ្ឌ ១៣២។

[123] ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៧៣។

[124] ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៧៥។

ដំណោះស្រាយទីពីរមិនអាចទៅរួច ពេលនោះដំណោះស្រាយតែមួយគត់សម្រាប់អង្គជំនុំជម្រះតុលាការកំពូល គឺកោះហៅ ហេង សំរិន ឲ្យចូលមកផ្តល់សក្ខីកម្មលើបណ្តឹងសាទុក្ខ។ ការទទួលខុសត្រូវនេះពុំអាចទម្លាក់ទៅអ្នកណាផ្សេងទៀតបានឡើយ

45. ជាសរុបមក មេធាវីការពារក្តីសូមលើកឡើងថា ភស្តុតាងរបស់ ហេង សំរិន គឺមានសារៈសំខាន់ណាស់ អាចជឿជាក់បាន មានភាពពាក់ព័ន្ធ មានតែមួយគត់ ដែលថា គ្មានហេតុផលស្របច្បាប់ណាមួយសម្រាប់អង្គជំនុំជម្រះតុលាការកំពូលអាចយោងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនក្នុងការមិនកោះហៅកាត់មកផ្តល់សក្ខីកម្មនៅក្នុងបណ្តឹងសាទុក្ខឡើយ។

## ខ. សំណើសុំការពិចារណាឡើងវិញអំពីសេចក្តីសម្រេចមិនកោះហៅ Robert Lemkin និងមិនទទួលយកជាភ័ស្តុតាងនូវកំណត់ត្រា និងប្រតិចារឹកនៅសល់របស់គាត់

46. ដូចករណី ហេង សំរិន ដែរ មេធាវីការពារក្តីក៏បានធ្វើសារណាជាច្រើនស្តីពីសារៈសំខាន់នៃសក្ខីកម្ម និងភ័ស្តុតាងរបស់ Robert Lemkin សម្រាប់សវនាការលើសំណុំរឿង ០០២/០១ និងបានស្នើសុំឱ្យគាត់ចូលមកបង្ហាញខ្លួន និងស្នើសុំការស្រាវជ្រាវអំពីវត្ថុតាងដែលគាត់មាន។ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើទាំងនេះទាំងស្រុង[125]។ ផ្ទុយទៅវិញ ដំណោះស្រាយ (យ៉ាងហោចណាស់ ក៏ជាដំណោះស្រាយបឋម) របស់អង្គជំនុំជម្រះតុលាការកំពូល ចំពោះលោក Lemkin បានឃ្លាតចាកយ៉ាងឆ្ងាយពីដំណោះស្រាយរបស់អង្គជំនុំជម្រះសាលាដំបូង។ ជាពិសេស បន្ទាប់ពីការពិភាក្សាសម្រេចចំនួនប្រាំពីរខែ នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានឯកភាពសំណើសុំភ័ស្តុតាងបន្ថែមលើកទីមួយរបស់មេធាវីការពារក្តី[126] ដែលបានដាក់នៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៤ បន្ទាប់ពីមានកិច្ចសម្ភាសន៍របស់វិទ្យុសំឡេងសហរដ្ឋអាមេរិកជាមួយ ថេត សម្បត្តិ ដើម្បីបើកកិច្ចស៊ើបសួរទៅលើឈុតខ្សែវីដេអូរបស់លោក សម្បត្តិ និងលោក Lemkin[127]។

---

[125] ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ៨៣។ *សូមមើលផងដែរ* ឯកសារ E294, "សំណើសុំទទួលយកភ័ស្តុតាងថ្មីកោះហៅ ROB LEMKIN និងចាប់ផ្តើមការស៊ើបអង្កេត", ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣។ ឯកសារ **E295/6/3**, សារណាបញ្ចប់ការពិភាក្សាដេញដោល, កថាខណ្ឌ ៤៨-៤៩។

[126] ឯកសារ **F2/4/3**, សេចក្តីសម្រេចបណ្តោះអាសន្នអំពី Lemkin-សម្បត្តិ, កថាខណ្ឌ ២៦។

[127] ឯកសារ **F2**, សំណើភ័ស្តុតាងបន្ថែម, កថាខណ្ឌ ១៨។

ថៅក្រមពីររូបនៃអង្គជំនុំជម្រះនេះ បានស្តាប់ចម្លើយរបស់លោក Lemkin[128]។ ទោះបីជាលោក Lemkin ពុំបានប្រគល់ឈុតខ្សែវីដេអូ ដែលបានស្នើសុំនោះជូនអង្គជំនុំជម្រះ បន្ទាប់ពីគ្មានការយល់ព្រមពីលោក ថេត សម្បត្តិ ក៏ដោយ[129] ក៏លោក Lemkin បានប្រគល់ជូនអង្គជំនុំជម្រះនូវសំណៅនានានៃកំណត់សម្គាល់ របស់គាត់[130] និងប្រតិចារឹកចំនួន១៨៩ទំព័រ[131] ដែលអង្គជំនុំជម្រះបានបង្ហាញទៅភាគីដោយសម្ងាត់យ៉ាងត្រឹមត្រូវ។

47. តបសំណើជាច្រើនរបស់អង្គជំនុំជម្រះសុំឱ្យដាក់សារណាស្តីពីប្រធានបទនេះ[132] មេធាវីបានពន្យល់យ៉ាងវែងអន្លាយក្នុងអំឡុងដំណើរការបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០១ ស្តីពីភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៃភស្តុតាងរបស់លោក Lemkin[133]។ ប៉ុន្តែជាថ្មីម្តងទៀត វាហាក់ដូចជាថា ជំហររបស់មេធាវីការពារក្តីលើបញ្ហានេះ និងបរិបទពាក់ព័ន្ធ អាចស័ក្តិសមនឹងការបញ្ជាក់ជាថ្មី។

### *(i) សារៈសំខាន់ និងមានតែមួយគត់ចេញពីភស្តុតាងរបស់ Robert Lemkin*

48. ដូចដែលមេធាវីការពារក្តីបានពន្យល់ក្នុងសំណើរបស់ខ្លួន ដែលត្រូវបានច្រានចោល សុំឱ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅលោក Lemkin មកផ្តល់សក្ខីកម្ម និងស៊ើបសួរអំពីឈុតខ្សែវីដេអូដែលគាត់មាន នៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៣ លោក Lemkin បានផ្ញើសារអេឡិចត្រូនិកមួយច្បាប់ដោយស្ម័គ្រចិត្តមកលោក Koppe។ *ក្នុងចំណោមប្រការផ្សេងៗ* លោក Lemkin

---

[128] ឯកសារ F2/4/3/1, “កំណត់ហេតុស្តាប់ចម្លើយសាក្សី-Robert T.F. Lemkin” , ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥ (“កំណត់ហេតុស្តាប់ចម្លើយ Lemkin”)។

[129] ឯកសារ **F2/4/3/2**, “របាយការណ៍ឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ឯកសារ **F2/4/3/2**” ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥។

[130] ឯកសារ **F2/4/3/3.1**, “សម្ងាត់-កំណត់ហេតុដែលពុំត្រូវបានបោះពុម្ពផ្សាយស្តីពីការស៊ើបអង្កេតអំពីទំនាស់ផ្ទៃក្នុងរបស់ខ្មែរក្រហម”, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ (“កំណត់សម្គាល់”)។

[131] ឯកសារ **F2/4/3/3/6.2**, “របាយការណ៍ឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ឯកសារ F2/4 /3 /3/5/1”, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥។

[132] ឯកសារ **F2/4/3/3**, “សេចក្តីសម្រេចស្នើឱ្យដាក់សារណាស្តីពីកិច្ចស៊ើបសួរបន្ថែម”, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥។ ឯកសារ **F/2/4/3/3/6**, “សេចក្តីសម្រេចស្នើឱ្យដាក់សារណា”, ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៥។

[133] *សូមមើល* ឯកសារ **F2/4/3/3/1**, ចម្លើយតបលើកំណត់ហេតុ Lemkin, ឯកសារ **F2/4/3/3/4**, សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព លើកំណត់សម្គាល់ Lemkin,ឯកសារ **F2/4/3/3/6/1**, សារណាអំពីប្រតិចារឹក និង “ជម្លោះ”។

បានគូសបញ្ជាក់ថា៖

> ទាក់ទិននឹងពោធិ៍ជ្រៃ គឺជាកន្លែងសម្លាប់រង្គាលក្រោមបញ្ជារបស់ រស់ ញឹម ពុំ មែន ក្រោម បញ្ជារបស់មជ្ឈិមបក្សឡើយ។ យើងបានប្រមូលភ័ស្តុតាងជាច្រើនអំពីផែនការរបស់ ញឹម ប៉ុន្តែរហូតមកទល់ពេលនេះ យើងមិនទាន់បានបញ្ចប់ខ្សែភាពយន្តទីពីររបស់យើង ពីព្រោះតែ [កោសលប់] បានទៅសហរដ្ឋអាមេរិក ដោយសារមូលហេតុផ្ទាល់ខ្លួន"[134]។

49. សារអេឡិចត្រូនិករបស់ Lemkin ស៊ីសង្វាក់ជាមួយព័ត៌មានដែល សហផលិតករខ្សែភាពយន្តរបស់គាត់ ថេត សម្បត្តិ បានប្រាប់ *សំឡេងសហរដ្ឋអាមេរិក* មួយឆ្នាំ ក្រោយមកទៀតក្នុងខែ សីហា ឆ្នាំ ២០១៤ ប៉ុន្មានថ្ងៃក្រោយពេលមានសាលក្រម។ ដូចដែលបានកត់សម្គាល់ខាងលើ លោក សម្បត្តិ បានពន្យល់ថា "អ្នកដែលផ្តួចផ្តើមគំនិតទៅសម្លាប់ទាហាន លន់ នល់ មិនមែន នួន ជា ទេ ... មានមនុស្សជាច្រើននៅក្នុងរដ្ឋាភិបាលដែលផ្តួចផ្តើមគំនិតសម្លាប់ប្រជាជន អ្នកអស់ណ្ហឹងនៅរស់"[135] ហើយថា ឯកសារភាពយន្តទីពីរនឹង "បង្ហាញអំពីជម្លោះ ដែលគេហៅថាសង្គ្រាមស៊ីវិលសម្ងាត់នៅក្នុងរបបខ្មែរក្រហម ហៅថាជម្លោះផ្ទៃកនយោបាយនៅក្នុងរបបខ្មែរក្រហម។ ហើយនឹងបង្ហាញអំពីអ្វីដែលនៅពីខាងក្រោយការកាប់សម្លាប់នោះ"[136]។

50. ក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់គាត់ចំពោះចៅក្រមតំណាងអង្គជំនុំជម្រះតុលាការកំពូល លោក Lemkin បានបញ្ជាក់អះអាងថា គាត់ និងលោក សម្បត្តិ ពិតជាបាន "ប្រមូលបានភ័ស្តុតាងជាច្រើនទាក់ទងនឹងរបៀបវារៈនយោបាយរបស់ រស់ ញឹម ក្នុងអំឡុងរយៈកាលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៨"។ លោក Lemkin បានលើកឡើងអំពីការសម្ភាសន៍ជាមួយបុគ្គលចំនួន ៤ រូបដែលលោក Lemkin បាននិយាយថា៖

> បានដឹងអំពីរបៀបវារៈនយោបាយរបស់ រស់ ញឹម ទាក់ទងការយល់ឃើញរបស់ រស់ ញឹម អំពីការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា, ការយល់ឃើញរបស់ រស់ ញឹម អំពីមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា, ការយល់ឃើញរបស់ រស់ ញឹម អំពីអ្វីដែលត្រូវធ្វើចំពោះមាគ៌ានោះ, ការយល់ឃើញ និងសកម្មភាពនានារបស់

---

[134] ឯកសារ E294, "សំណើសុំទទួលយកភ័ស្តុតាងថ្មី កោះហៅ Rob Lemkin និងចាប់ផ្តើមការស៊ើបអង្កេត", ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១៣, កថាខណ្ឌ ២ (សាធារណៈ (កោសលប់)) (សេចក្តីបញ្ជាក់បន្ថែម)។

[135] ឯកសារ **F2**, សំណើភ័ស្តុតាងបន្ថែមលើកទីមួយ, ទំព័រ ៥ (សេចក្តីបញ្ជាក់បន្ថែម)។

[136] ឯកសារ **F2**, សំណើភ័ស្តុតាងបន្ថែមលើកទីមួយ, ទំព័រ ៧ (សេចក្តីបញ្ជាក់បន្ថែម)។

រស់ ញឹម ក្នុងការប៉ុនប៉ងដណ្តើមគ្រប់គ្រងបក្ស[137]។

51. កំណត់សម្គាល់ទាំងនេះ ដែលសង្ខេបអំពីការរៀបរាប់របស់បុគ្គលទាំង៤រូបនោះបង្ហាញថា សោ ភឹម និង រស់ ញឹម បានបើកការប្រជុំមួយដោយគ្មានការខ្លាចក្រែង នៅក្នុងទីក្រុងភ្នំពេញ ក្នុងខែឧសភា ឆ្នាំ ១៩៧៥ ដែលអ្នកចូលរួមសុទ្ធតែជាមន្ត្រីជាន់ខ្ពស់ចំនួនរាប់រយនាក់ បានប្តេជ្ញាដើម្បីធ្វើរដ្ឋប្រហារ តាមរយៈបក្សសម្ងាត់ដាច់ដោយឡែកមួយ និងវិធានការជាក់ស្តែង ឬវិធានការបម្រុងជាច្រើនត្រូវបានធ្វើឡើងដើម្បីឆ្ពោះទៅរកការបះបោរ[138]។ ប្រតិចារឹកទាំងនេះជាអត្ថបទបកប្រែពីភាសាអង់គ្លេសដែលធ្វើប្រតិចារឹកឈុតខ្សែវីដេអូនៃកិច្ចសម្ភាសន៍ជាមួយបុគ្គលទាំង៤រូបនោះ និងផ្តល់រូបភាពពេញលេញនៃកិច្ចសម្ភាសន៍។

52. ដូចដែលមេធាវីការពារក្តីបានលើកទឡ្ហីករណ៍ក្នុងអំឡុងដំណើរការបណ្តឹងសាទុក្ខ កំណត់សម្គាល់ និងប្រតិចារឹកគាំទ្រអំណះអំណាងជាមូលដ្ឋានរបស់ នួន ជា ដែលថា ប.ក.ក ត្រូវបានធ្វើឲ្យក្រឡាប់ចាក់ដោយការបែកបាក់ផ្ទៃក្នុង និងត្រូវបានបំផ្លាញដោយការបង្កការបះបោរដើម្បីឈានដល់ការធ្វើរដ្ឋប្រហារ ក្រោមការដឹកនាំរបស់ សោ ភឹម និង រស់ ញឹម និងឧបត្ថម្ភដោយវៀតណាម។ នៅក្នុងសាលក្រម អង្គហេតុទាំងនេះបង្កើតបានជាការងាកចេញភ្លាមៗពីបក្សដែលត្រូវបានរៀបចំឡើងយ៉ាងប៉ិនប្រសប់ ជាអង្គភាពដែលមានរចនាសម្ព័ន្ធ "ឋានានុក្រម" តឹងរ៉ឹង និង "មានទម្រង់ជាពីរ៉ាមីត" ដែលកម្មាភិបាលនៅទូទាំងប្រទេស និងក្នុងអំឡុងពេលនៃរបបនេះ ធ្វើសកម្មភាពយ៉ាងខ្ជាប់ខ្ជួនដែលបង្កើតឡើងដោយ ប៉ុល ពត និង នួន ជា[139]។ ដូចដែលបណ្តឹងសាទុក្ខបង្ហាញភស្តុតាងដែលលើកមកសំអាងដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការគាំទ្រសេចក្តីសន្និដ្ឋានទូលំទូលាយបែបនេះ ដែលសំខាន់ណាស់សម្រាប់ការរកឃើញរបស់ខ្លួនទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា លើការសម្លាប់ទៅទួលពោធិជ្រៃ គឺស្ងួចស្តើងសឹងតែបាត់មួយរំពេច[140]។

53. សហព្រះរាជអាជ្ញាបានបង្ខូចភស្តុតាងរបស់ លោក Lemkin ក្នុងការប៉ុនប៉ងកាន់តែខ្លាំងក្លាដើម្បីធ្វើឲ្យប៉ះពាល់ដល់ភាពអាចជឿជាក់បាននៃកំណត់សម្គាល់ និងប្រតិចារឹកទាំងនោះ និងអាស្រ័យ

---

[137] ឯកសារ **F2/4/3/1**, កំណត់ហេតុស្តាប់ចម្លើយរបស់ Lemkin។

[138] *សូមមើល ឧទាហរណ៍* ឯកសារ **F2/8**, សំណើសុំភស្តុតាងបន្ថែមលើកទីប្រាំមួយ, កថាខណ្ឌ ៣១, ៣៣, ៣៧-៤០។

[139] *សូមមើល ឧទាហរណ៍* ឯកសារ **E313**, សាលក្រម, កថាខណ្ឌ ២២៣, ៨៥៩-៨៦០។ *សូមមើលផងដែរ* ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ២២៥-២៤៩។

[140] ឯកសារ **F16**, បណ្តឹងសាទុក្ខ, កថាខណ្ឌ ២២៥-២៤៩។

ហេតុនេះច្រានចោលឯកសារទាំងនោះទាំងស្រុងតែម្តង[141]។ នេះជាការចម្លែកណាស់ ពីព្រោះកន្លងមកសហព្រះរាជអាជ្ញាធ្លាប់បានព្យាយាមសំអាងយ៉ាងច្រើនលើឈុតខ្សែវីដេអូរបស់ Robert Lemkin និង ថេត សម្បត្តិ ក្នុងអំឡុងសវនាការលើសំណុំរឿង ០០២/០១[142]។ ក្នុងករណីណាក៏ដោយ មេធាវីការពារក្តីបានផ្តល់សេចក្តីបដិសេធដោយប្រុងប្រយ័ត្នចំពោះអំណះអំណាងនីមួយៗរបស់សហព្រះរាជអាជ្ញា។ មេធាវីការពារក្តីបានបញ្ជាក់លម្អិតអំពីជំនាញជាក់លាក់របស់លោក Lemkin ក្នុងនាមជាផលិតករភាពយន្តដែលបានទទួលការអប់រំពីសាកលវិទ្យាល័យ Oxford និងជាអ្នកសារព័ត៌មាន ដែលមានបទពិសោធន៍វិជ្ជាជីវៈជាច្រើនទសវត្សរ៍ និងដែលជាបងប្អូនជីដូនមួយជាមួយ Raphael Lemkin (ដែលបានបង្កើតពាក្យ "ប្រល័យពូជសាសន៍" ដែលជាកេរ្តិ៍តំណែល "នាំឲ្យគាត់ការងាររបស់ផលិតករ")[143] ។ មេធាវីការពារក្តីបានសង្ខេបអំពីវិធីសាស្ត្រលម្អិត ដែលត្រូវបានប្រើប្រាស់ក្នុងការស្តាប់ចម្លើយរួមទាំងការខិតខំដើម្បី "ផ្ទៀងផ្ទាត់ ឬបន្ថែម" សក្ខីកម្មរបស់ពួកគាត់[144] និងការជាប់ពាក់ព័ន្ធដ៏ស្និតរមួតរបស់លោក Lemkin នៅគ្រប់ដំណាក់កាលនៃដំណើរការសម្ភាសន៍[145]។ មេធាវីការពារក្តីក៏បានបង្ហាញអំពីភាពពុំសមទំនងនៃការប៉ុនប៉ង

---

[141] មេធាវីការពារក្តីបានសង្ខេបអំពីការចោទប្រកាន់ដ៏ធ្ងន់ធ្ងរ និងមិនត្រឹមត្រូវរបស់សហព្រះរាជអាជ្ញាលើបញ្ហានេះនៅឯកសារ **F2/8/6**, "សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទីប្រាំមួយ ពាក់ព័ន្ធនឹងភ័ស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១", ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ ("សារណាឆ្លើយតបចម្លើយតប ក.ស.ព ទៅនឹងសំណើសុំភ័ស្តុតាងបន្ថែមលើកទីប្រាំមួយ") ជើងទំព័រ ២២។

[142]ឯកសារ **F2/4/3/3/4**,សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព លើកំណត់សម្គាល់របស់ Lemkin, កថាខណ្ឌ ១៣-១៥។ ឯកសារ **F2/8/6**, សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំភ័ស្តុតាងបន្ថែមលើកទីប្រាំមួយ, ជើងទំព័រ ២២។

[143] ឯកសារ **F2/4/3/3/4**, សារណាឆ្លើយតបទៅនឹងចម្លើយតប ក.ស.ព អំពីកំណត់សម្គាល់របស់ Lemkin, កថាខណ្ឌ ១១។ ឯកសារ **F2/4/3/3/4.1.2**, Naomi Pfefferman, " រឿងប្រល័យពូជសាសន៍របស់ Lemkin លើកទីពីរ និយាយអំពី "សត្រូវ", *Jewish Journal,* ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ មាននៅលើគេហទំព័រ៖ http://www.jewishjournal.com/film/article/the_second_lemkins_genocide_story_frames_the_enemies_20110113។

[144] ឯកសារ **F2/4/3/3/4**, សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព អំពីកំណត់សម្គាល់របស់ Lemkin, កថាខណ្ឌ ១១។

[145] ឯកសារ **F2/4/3/3/4**, សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព អំពីកំណត់សម្គាល់របស់ Lemkin, កថាខណ្ឌ ១២។

របស់សហព្រះរាជអាជ្ញាដើម្បីបែងចែករវាងជំនាញរបស់លោក Lemkin និងសម្បត្តិ[146] ការចាត់ទុកការសម្ភាសន៍ទាំងនោះ "គ្រាន់តែជាសំដីមួយរបស់ នួន ជា"[147] និងកាន់តែខុសឆ្គងជាងនេះទៀត គឺការលើកឡើងថា ការសម្ភាសន៍ទាំងនោះមិនភាពអាចជឿជាក់បាន *តិច* ជាងការសម្ភាសន៍ដែលធ្វើឡើងដោយ Stephen Heder, Philip Short និង Francois Ponchaud និងដែលត្រូវបានលើកយកមកសំអាងយ៉ាងច្រើនក្នុងសាលក្រម (នៅពេលដែលការសម្ភាសន៍របស់លោក Lemkin និង សម្បត្តិ ដែលជាការសម្ភាសន៍ថ្មីៗបំផុត ដែលផ្អែកលើសក្ខីកម្មរបស់សាក្សីផ្ទាល់ភ្នែក ជាជាងពាក្យចចាមអារាម និងជាការសម្ភាសន៍តែមួយគត់ដែលត្រូវបានថតជាវីដេអូ)[148]។

54. បន្ថែមពីលើនេះ មេធាវីការពារក្តីបានកត់សម្គាល់រួចហើយថា បញ្ហាការពារនានាទាក់ទងបុគ្គលចំនួន ៣ រូបក្នុងចំណោមបុគ្គលចំនួន ៤ រូប ដែលត្រូវបានសម្ភាសន៍ ហាក់ដូចជាត្រូវបានចាត់ជាមោឃៈ ដោយហេតុថា សក្ខីកម្មរបស់ពួកគាត់ត្រូវបានបង្ហាញរួចហើយក្នុងសៀវភៅរបស់ ថេត សម្បត្តិ និង Gina Chon ដែលមានចំណងជើងថា *Behind the Killing Fields*[149] ដែលត្រូវបានបញ្ចេញជាសាធារណៈចាប់តាំងពីពេលចេញផ្សាយក្នុងឆ្នាំ ២០១០។ ជាការពិត សាក្សីម្នាក់ក្នុងចំណោមសាក្សីទាំង ៣រូប ឈ្មោះ ទាត់ ធឿន បានផ្តល់សក្ខីកម្មលើបណ្តឹងសាទុក្ខរួចទៅហើយ បើទោះជាសក្ខីកម្មរបស់គាត់នៅក្នុងសវនាការមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងពីអ្វី ដែលគាត់បាននិយាយនៅក្នុងកាម៉េរ៉ារបស់ Lemkin និង សម្បត្តិ[150]។ ជាងនេះទៀត ក្នុងករណីចាំបាច់ តុលាការអាចបង្គាប់ឲ្យមានការអនុវត្តវិធានការការពារដែលមានដើម្បីទទួលបានសក្ខីកម្មរបស់បុគ្គលទីបួន[151]។

---

[146] ឯកសារ **F2/4/3/3/4**, សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព អំពីកំណត់សម្គាល់របស់ Lemkin, កថាខណ្ឌ ១៥។

[147] ឯកសារ **F2/4/3/3/4**, សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព អំពីកំណត់សម្គាល់របស់ Lemkin, កថាខណ្ឌ ១៥។

[148] ឯកសារ **F2/4/3/3/4**, សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព អំពីកំណត់សម្គាល់របស់ Lemkin, កថាខណ្ឌ ១៧-២០។

[149] ឯកសារ **E3/4202**, Gina Chon និង ថេត សម្បត្តិ, *Behind the Killing Fields: A Khmer Rouge Leader and One of his Victims*, ឆ្នាំ ២០១១។

[150] ឯកសារ **F2/4/3/3/6/1**, សារណាអំពីប្រតិចារឹក និង "ជម្លោះ" , កថាខណ្ឌ ១១។

[151] ឯកសារ **F2/4/3/3/6/1**, សារណាអំពីប្រតិចារឹក និង "ជម្លោះ" , កថាខណ្ឌ ៩។

*(ii) កំហុសក្នុងការសម្រេចមិនកោះហៅ* **Robert Lemkin** *ឬក៏ទទួលភស្តុតាងកំណត់ត្រា និងប្រតិចារិកនៅសល់*

55. ជាសរុប សក្ខីកម្ម និងកំណត់សម្គាល់ និងប្រតិចារឹករបស់លោក Lemkin មានភាពពាក់ព័ន្ធខ្លាំង និងអាចជឿជាក់បាន និងចាក់ចំបេះដូងនៃសំណុំរឿងរបស់មេធាវីការពារក្តី។ ដូចដែលមេធាវីការពារក្តីបានកត់សម្គាល់រួចមកហើយ ពិសេសក្នុងសំណើសុំភស្តុតាងបន្ថែមលើកទីប្រាំមួយរបស់ខ្លួន ព័ត៌មានដែលថា លោក Lemkin, កំណត់ត្រា និងប្រតិចារឹកនៅសល់អាចផ្តល់គឺកំពុងត្រូវបានផ្ទៀងផ្ទាត់ ជាមួយភស្តុតាង ដែលត្រូវបានទទួលយកក្នុងសំណុំរឿង ០០២/០២ ពីកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង០០៤ និងតាមរយៈឯកសារនានាក្នុងមជ្ឈដ្ឋានសាធារណៈ ក្នុងនោះរួមទាំងកិច្ចការរបស់អ្នកស្រាវជ្រាវ របាយការណ៍សារព័ត៌មាន របាយការណ៍ស៊ើបការណ៍ និងទូរលេខការទូត(ត្រូវបានបង្ហាញក្នុងពេលថ្មីៗ)[152]។ អង្គជំនុំជម្រះតុលាការកំពូលបានខិតខំយ៉ាងសកម្ម ដើម្បីទទួលបានព័ត៌មាន ដែលលោក Lemkin បានដឹង។ អាស្រ័យហេតុនេះ ក្រោមកាលៈទេសៈទាំងនេះ មេធាវីការពារក្តីពុំអាចមើលឃើញមូលដ្ឋានប្រកបដោយសុពលភាពណាមួយចំពោះការសម្រេចរបស់អង្គជំនុំជម្រះមិនកោះ ហៅលោក Lemkin ជាសាក្សី ឬមិនទទួលយកជាភស្តុតាងនូវកំណត់សម្គាល់ ឬប្រតិចារឹកចំនួន ៣ ឡើយ។ ការកោះហៅលោក Lemkin ឲ្យមកផ្តល់សក្ខីកម្មក្នុងសវនាការលើបណ្តឹងសាទុក្ខមានភាពចាំបាច់-ក្នុងករណីចាំបាច់ គាត់អាចផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ដើម្បីមេធាវីការពារក្តីយ៉ាងហោចណាស់មានឱកាសសួរដេញដោលគាត់។ ការទទួលយកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ នូវកំណត់សម្គាល់ និងប្រតិចារឹករបស់គាត់ ក៏ជាការសំខាន់ដូចគ្នា។ ការខកខានជាបន្តបន្ទាប់របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការធ្វើដូច្នោះ នឹងមិនត្រឹមតែរំលោភ យ៉ាងជាក់ស្តែងដល់សិទ្ធិ នួន ជាក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ តាមរយៈការហាមឃាត់មិនឲ្យការពារក្តីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញអំពីភាពត្រឹមត្រូវនៃការវាយតម្លៃរបស់លោក Lemkin ក្រោយពីមានសេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម។ លោក Lemkin បានវាយតម្លៃថា៖

> ខ្ញុំអាចត្រឹមតែសន្និដ្ឋានថា តាមការពិត អ.ជ.ត.ក គ្រាន់តែជាអ្នកស៊ើបការណ៍ប៉ុណ្ណោះ-ដោយបានប្រមូលយកព័ត៌មាននានា និងពុំស្ថិតនៅលើផ្លូវឆ្ពោះទៅស្វែងរកការពិតអំពីជំនាន់ខ្មែរក្រហមឡើយ [...]

---

[152] *សូមមើល* ឯកសារ **F2/8**, សំណើសុំដាក់ភស្តុតាងបន្ថែមលើកទីប្រាំមួយ, កថាខណ្ឌ ២៤-១៤៨។

អ.វ.ត.ក ហាក់បីដូចជាពេញចិត្តប្រើប្រាស់វត្ថុតាងពីខ្សែវីដេអូទាំងនោះដោយមានការរើសអើង និងដោយពុំត្រឹមត្រូវជារឿយៗ នៅពេលវត្ថុតាងនោះជួយដល់ការចោទប្រកាន់។ នៅពេលវត្ថុតាងនោះមិនជួយដល់ការចោទប្រកាន់-ដោយមិនមែនចៃដន្យ ចាកឆ្ងាយពីពិរុទ្ធភាពរបស់ជនជាប់ចោទ-តុលាការច្រានចោល[153]។

56. ជាសរុបមក ដូចគ្នានឹងភស្តុតាងរបស់ ហេង សំរិន ដែរ មេធាវីការពារក្តីសូមលើកឡើងថា ភស្តុតាងរបស់ Robert Lemkin គឺមានសារៈសំខាន់ណាស់ អាចជឿជាក់បាន មានភាពពាក់ព័ន្ធ មានតែមួយគត់ ដែលថា គ្មានហេតុផលស្របច្បាប់ណាមួយសម្រាប់អង្គជំនុំជម្រះតុលាការកំពូលអាចយោងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ក្នុងការមិនកោះហៅកាត់មកផ្តល់សក្ខីកម្មនៅក្នុងបណ្តឹងសាទុក្ខ ឬក៏ទទួលយកកំណត់ត្រារបស់គាត់ និង ប្រតិចារិកទាំងប៉ុន្មានចូលក្នុងសំណុំរឿងឡើយ។

## គ. ជាជម្រើសមួយទៀត គឺការផ្តល់សំអាងហេតុពេញលេញចំពោះសេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម

57. ដូចដែលបានពិភាក្សាខាងលើ សំណើសុំភស្តុតាង និងសាក្សីបន្ថែមដែលត្រូវបានឆ្លើយតបក្នុងសេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម មានសារៈសំខាន់ធំធេងចំពោះសំណុំរឿងរបស់មេធាវីការពារក្តី ហើយអាចជាកត្តាសម្រេចមួយក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន។ ហេតុដូច្នេះ ការទទួលយកភស្តុតាងនេះ ចាំបាច់សម្រាប់ នួន ជា អាចអនុវត្តសិទ្ធិរបស់គាត់បានពេញលេញដើម្បីពិនិត្យមើលសាលក្រម។ អាស្រ័យហេតុនេះ មេធាវីការពារក្តីជឿជាក់ថា សេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម ស្ថិតក្នុងប្រភេទនៃសេចក្តីសម្រេចដែលមេធាវីការពារក្តីគួរមានសិទ្ធិទទួលបានសំអាងហេតុ។ ពាក់ព័ន្ធបញ្ហាពេលវេលា មេធាវីការពារក្តីសូមអះអាងថា សំអាងហេតុត្រូវផ្តល់ជាចាំបាច់ឲ្យបានមុនពេលបន្តសវនាការលើបណ្តឹងសាទុក្ខ ដោយហេតុថា ពេលសវនាការបណ្តឹងសាទុក្ខចប់ មេធាវីការពារក្តីក៏អស់ឱកាសដើម្បីដាក់សារណាជាលាយលក្ខណ៍អក្សរជូនអង្គជំនុំជម្រះតុលាការកំពូលផងដែរ[154]។ ដោយយោងទៅលើសារៈសំខាន់នៃសំណើទាំងនេះចំពោះមេធាវីការពារក្តី សំអាងហេតុដែលផ្តល់ដោយអង្គជំនុំជម្រះចំពោះការច្រានចោលសំណើទាំងនេះ អាចធ្វើឲ្យមានសំណើនានាពីសំណាក់មេធាវីការពារក្តី ស្នើសុំពិចារណាឡើងវិញអំពីចំណុចដទៃទៀតនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ តាមហេតុផលនេះ ការផ្តល់សំអាងហេតុឲ្យបានមុន

---

[153] Robert Lemkin, " លិខិតផ្ញើទៅសារព័ត៌មាន៖ Robert Lemkin" , *ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥, នៅលើគេហទំព័រ http://www.phnompenhpost.com/analysis-and-op-ed/letter-editor-rob-lemkin ។

[154] *សូមមើល ខាងលើ* ត្រង់ជើងទំព័រ ២៤។

ការបន្តសវនាការបណ្តឹងសាទុក្ខ ជាការចាំបាច់ដើម្បីផ្តល់ឱកាសដ៏ពិតប្រាកដមួយសម្រាប់មេធាវីការពារក្តីធ្វើការព្យាយាមជាលើកចុងក្រោយដើម្បីតទល់ក្តី លើបញ្ហាសំខាន់ៗទាំងអស់នេះ បើទោះបីវាជាឱកាសដ៏ខ្លីក៏ដោយ។ ពិតណាស់មេធាវីការពារក្តី មេធាវីការពារក្តីគិតថា នៅក្រោមវិធាន ១០៨(៤) អង្គជំនុំជម្រះតុលាការកំពូលមានកាតព្វកិច្ចក្នុងការផ្តល់យ៉ាងហោចណាស់ក៏សម្អាងហេតុសង្ខេបនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើសំណើដែលមិនទាន់សម្រេច និងត្រូវចេញសម្អាងហេតុពេញលេញ ឲ្យបានឆាប់តាមលទ្ធភាពអាចធ្វើបាននៅពេលក្រោយ។

## VI. ដំណោះស្រាយ

58. មេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះតុលាការកំពូល៖

(ក) ពិចារណាសេចក្តីសម្រេចរបស់ខ្លួនឡើងវិញ

(i) ក្នុងការមិនកោះហៅសាក្សី ហេង សំរិន និង Robert Lemkin និង

(ii) ក្នុងការមិនទទួលយកជាភស្តុតាងនូវកំណត់សម្គាល់ និងប្រតិចារឹករបស់លោក Lemkin ឬជាជម្រើសមួយទៀត

(ខ) ផ្តល់សំអាងហេតុពេញលេញជាបន្ទាន់ចំពោះសេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម មុនពេលបន្តសវនាការលើបណ្តឹងសាទុក្ខ។

**សហមេធាវីរបស់ នួន ជា**

**សុន អរុណ** **Victor KOPPE**